ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ឃុំកណ្តាល

និងឯកសារពាក់ព័ន្ធ

ឈ្មោះសហគមន៍នេសាទ : ឃុំកណ្តាល

ភូមិ : កណ្តាល ប្រលាន ផ្ទង់

ឃុំ : កណ្តាល

ស្រុក : បុទុមសាគរ

ខេត្ត : កោះកុង

បញ្ជីអត្ថបទ

១- កិច្ចព្រមព្រៀងកន្លែងសហគមន៍ទេសាទ

២- ផែនទីកន្លែងសហគមន៍ទេសាទ

៣- បញ្ជីឈ្មោះសមាជិក គណៈកម្មការសហគមន៍ និងរចនាសម្ព័ន្ធ

៤- លក្ខន្តិកៈសហគមន៍ទេសាទ

៥- បទបញ្ជាផ្ទៃក្នុងសហគមន៍ទេសាទ

៦- សេចក្តីថ្លែងការណ៍នៃការបង្កើតសហគមន៍ទេសាទ

៧- ឯកសារផ្សេងៗ

កិច្ចព្រមព្រៀង
កន្លែងនេសាទសហគមន៍

រ វ ា ង

នាយខណ្ឌរដ្ឋបាលជលផលកោះកុង ជាតំណាងស្របច្បាប់នៃរដ្ឋបាលជលផល មានអាស័យដ្ឋាននៅ : ភូមិ ១ សង្កាត់ស្នាច់មានជ័យ ក្រុងខេមរ:ភូមិន្ទ ទូរស័ព្ទលេខ ០៣៥ ៩៣៦ ២៨៤ អ៊ីម៉ែល kk_fisheries@yahoo.com ហៅថា "ភាគី **ក**" ។

និង

ប្រធានគណ:កម្មការសហគមន៍នេសាទឃុំកណ្តាល ជាតំណាងស្របច្បាប់ឱ្យសហគមន៍នេសាទ ដែលមានអាស័យដ្ឋានស្ថិតនៅ : ឃុំកណ្តាល ស្រុកបូទុមសាគរ ខេត្តកោះកុង ទូរស័ព្ទលេខ ឬ ហៅថា "ភាគី **ខ**" ។

ភាគីទាំងពីរបានឯកភាពគ្នាចុះកិច្ចព្រមព្រៀងតាមលក្ខខណ្ឌដូចខាងក្រោម :

ប្រការ ១

ភាគី **ក** ប្រគល់ដែននេសាទដែលជាទ្រព្យសម្បត្តិរបស់រដ្ឋឱ្យភាគី **ខ** ធ្វើការគ្រប់គ្រង ការពារ អភិរក្ស អភិវឌ្ឍន៍ និងប្រើប្រាស់ធនធានជលផលរយ:ពេល ៣ ឆ្នាំ ចាប់ពីថ្ងៃទី.....ខែ.....ឆ្នាំ២០... រហូតដល់ថ្ងៃទី.....ខែ.....ឆ្នាំ ២០... ដោយធានានូវចីរភាពតាមរយ:ការរៀបចំសហគមន៍នេសាទ ។

ប្រការ ២

ដែននេសាទនេះមានឈ្មោះថា "**កន្លែងនេសាទសហគមន៍ ឃុំកណ្តាល** " ដែលលាតសន្ធឹង នៅក្នុង :

ភូមិ កណ្តាល ឃុំ កណ្តាល

ភូមិ ផ្ទង់ ឃុំ កណ្តាល

ភូមិ ប្រលាន ឃុំ កណ្តាល

មាននិយាមការដូចខាងក្រោម :

ល.រ	ចំណុចអាប់ស៊ីស	ចំណុចអរដោនេ
១	៣៣៧២៧៥	១២៣៤៣២១
២	៣៣៧៦៥៤	១២៣៤៧០១
៣	៣៤២៣៤០	១២៣៤០៩៤
៤	៣៣៩៥៥១	១២២៤៩៧០

ដូចមានផែនទីដែលបានភ្ជាប់មកជាមួយ ។

ប្រការ ៣

ភាគី **ក** ត្រូវបំពេញភារកិច្ចជាអ្នកជួយសម្របសម្រួល ផ្តល់បច្ចេកទេស ទប់ស្កាត់បទល្មើស តាមដាន និងត្រួតពិនិត្យលើការរៀបចំ និងការប្រព្រឹត្តទៅរបស់សហគមន៍នេសាទដូចមានចែងនៅក្នុងមាត្រា ២៣ នៃអនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៧ ស្តីពីការគ្រប់គ្រងសហគមន៍នេសាទ ។

ប្រការ ៤

ភាគី **ខ** ត្រូវរៀបចំ :

- កន្លែងអភិរក្សព្រៃលិចទឹក ឬព្រៃកោងកាង
- ស្រះ អាង អន្លង់ត្រីមេពូជ
- កន្លែងអភិរក្សជីវចំរុះ
- ស្តារប្រឡាយ ព្រែក បឹង ស្រះ
- ដាំព្រៃលិចទឹក
- ធ្វើវារីវប្បកម្ម
- បញ្ជូនសមាជិកសហគមន៍ ដើម្បីរៀនសូត្រនូវបច្ចេកទេសផលិតពូជត្រី
- ធានាគារក្តាម
- ការងារអភិវឌ្ឍន៍ផ្សេងៗទៀត ។

ប្រការ ៥

ភាគី **ខ** ត្រូវរៀបចំប្រជុំពិភាក្សាអំពីទំហំ ចំនួន ប្រវែង និងប្រភេទឧបករណ៍នេសាទ ដែលអនុញ្ញាតឱ្យប្រើប្រាស់នៅក្នុងកន្លែងនេសាទសហគមន៍ ឱ្យសមស្របតាមស្ថានភាពភូមិសាស្ត្រ និងពេលវេលា ផ្អែកតាមច្បាប់ស្តីពីជលផល និងលិខិតបទដ្ឋានគតិយុត្តិនានាដែលពាក់ព័ន្ធ ។

ប្រការ ៦

ភាគី **ខ** មានកាតព្វកិច្ចថែរក្សាការពារធនធានធម្មជាតិដូចខាងក្រោម :

- ការពារព្រៃលិចទឹក និងព្រៃកោងកាងដែលមានស្រាប់ឱ្យបានគង់វង្ស ចាត់វិធានការទប់ស្កាត់ និងបង្ការភ្លើងឆេះព្រៃ
- រក្សា និងការពារដីទំនាបលិចទឹក សម្រាប់ដាំព្រៃលិចទឹកឡើងវិញ
- លែងទៅក្នុងធម្មជាតិនូវវារីសត្វដែលកំពុងរងគ្រោះថ្នាក់ជិតផុតពូជ នៅពេលដែលធ្វើនេសាទបាន
- ការពារសត្វព្រៃគ្រប់ប្រភេទនៅក្នុងដែននេសាទ ឬព្រៃលិចទឹក និងព្រៃកោងកាង ។

ប្រការ ៧

ភាគី ខ មិនត្រូវធ្វើសកម្មភាពដែលបង្កឱ្យខូចដែននេសាទ ឬគ្រោះថ្នាក់ដល់ធនធានជលផល ដូចខាងក្រោម :

- ចាប់នូវធនធានជលផលដែលកំពុងរងគ្រោះថ្នាក់ ដូចមានចែងក្នុងប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាន់ និងនេសាទ ដូចជាផ្សាតជាដើម
- លើកទំនប់ លុប ឬជីកបឹង ព្រែក ប្រឡាយ រណ្តៅ ប្រេ ស្រះ ដែលពុំមានការអនុញ្ញាតពីស្ថាប័នជំនាញ
- កាប់ឆ្ការ គាស់ រាន ឈូសឆាយព្រៃលិចទឹក ឬព្រៃកោងកាងក្នុងគោលបំណងហ៊ុំព័ទ្ធយកដីជាកម្មសិទ្ធិ ឬវាតដីធ្វើស្រែចំការ ឬស្រែអំបិល ឬគោលបំណងផ្សេងៗទៀត
- ធ្វើនេសាទកាប់ព្រៃ ឬអុសក្នុងកន្លែងអភិរក្សជលផល ក្នុងកន្លែងនេសាទសហគមន៍
- ប្រើប្រាស់ឧបករណ៍ហាមឃាត់ ជាពិសេសឧបករណ៍នេសាទឆក់ត្រី និងឧបករណ៍នេសាទស្បៃមុងគ្រប់ប្រភេទ
- ចិញ្ចឹមត្រី ឬដាំសារាយដែលជាពូជនាំឱ្យខូចបរិស្ថានធម្មជាតិ បំផ្លិតបំផ្លាញដល់ធនធានជលផល ឬបង្កអន្តរាយដល់ដែននេសាទ
- ធ្វើនេសាទ ឬធ្វើអាជីវកម្មនេសាទផ្សេងៗទៀតដែលប៉ះពាល់ ឬរំខានដល់ការលូតលាស់នៃស្មៅសមុទ្រ ឬផ្កាថ្ម
- ប្រមូលផល ទិញ លក់ ដឹកជញ្ជូន និងធ្វើសន្និធិផ្កាថ្ម
- ផលិត ទិញ លក់ ដឹកជញ្ជូន រក្សាទុកឧបករណ៍ឆក់ ឧបករណ៍នេសាទស្បៃមុងគ្រប់ប្រភេទ ឈិបយន្ត និងអួនអូស
- ដាំ ឬថែរក្សាដំណាំឈូកក្នុងដែននេសាទ
- ធ្វើនេសាទដោយមង ឬអួនគ្រប់ប្រភេទដែលមានក្រឡាតូចជាង ១,៥ សង្ទីម៉ែត្រ និងធំជាងដប់ប្រាំ(១៥) សង្ទីម៉ែត្រ ក្នុងដែននេសាទទឹកសាប ។

ប្រការ ៨

ភាគី ខ ត្រូវចាត់វិធានការថែរក្សាការពារកន្លែងនេសាទសហគមន៍ ដោយបំផុស ជំរុញ និងលើកទឹកចិត្តដល់សមាជិកសហគមន៍នេសាទគ្រប់រូប ឱ្យរាយការណ៍ទៅសមត្ថកិច្ចរដ្ឋបាលជលផលដែលនៅជិតបំផុត ដើម្បីសហការទប់ស្កាត់បទល្មើសជលផល ។

ប្រការ ៩

ភាគី ខ ត្រូវអនុវត្តនូវការកិច្ចដូចខាងក្រោម :

- ប្រតិបត្តិយ៉ាងម៉ឹងម ម៉ាត់តាមលក្ខន្តិក: បទបញ្ជាផ្ទៃក្នុង និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- ធានាឱ្យសមាជិកទាំងអស់ក្នុងសហគមន៍មានសិទ្ធិស្មើគ្នា លើការប្រើប្រាស់ធនធានជលផល
- សហការយ៉ាងជិតស្និទ្ធជាមួយរដ្ឋបាលជលផល ក្រុមប្រឹក្សាឃុំ សង្កាត់ និងអាជ្ញាធរដែលពាក់ព័ន្ធ ។

ប្រការ ១០

ប្រសិនបើភាគី ខ មិនអនុវត្តតាមប្រការទាំងឡាយនៃកិច្ចព្រមព្រៀងនេះ ធ្វើឱ្យអន្តរាយដល់ដែននេសាទ ឬធនធានជលផល ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន ។

ប្រការ ១១

កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ អាចបញ្ឈប់មុនពេលកំណត់ដោយផ្អែកលើលក្ខខណ្ឌណាមួយ ដូចមានចែងក្នុងមាត្រា ២៧ នៃអនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៧ ស្តីពីការគ្រប់គ្រងសហគមន៍នេសាទ។

ក្នុងករណីដែលសហគមន៍នេសាទយល់ថា ការបញ្ឈប់កិច្ចព្រមព្រៀងពុំមានលក្ខណៈសមស្រប សហគមន៍នេសាទអាចធ្វើការតវ៉ាមកប្រធានរដ្ឋបាលជលផលថ្នាក់កណ្តាល ។

ប្រការ ១២

កិច្ចព្រមព្រៀងនេះអាចធ្វើការកែប្រែបានតាមការឯកភាពរបស់ភាគីទាំង ២ ស្របតាមច្បាប់ និងលិខិតបទដ្ឋាននានាពាក់ព័ន្ធនឹងសហគមន៍នេសាទ ។

កិច្ចព្រមព្រៀងនេះត្រូវតម្កល់ទុកនៅស្នាក់ការសហគមន៍នេសាទ សាលាឃុំ សង្កាត់ ខណ្ឌរដ្ឋបាលជលផល សាលាខេត្ត ក្រុង រដ្ឋបាលជលផលថ្នាក់កណ្តាល និងក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ហើយអាចចម្លងជូនស្ថាប័នពាក់ព័ន្ធដោយច្បាប់ចម្លងត្រូវមានប្រថាប់ត្រា ។

ថ្ងៃទី.....ខែ.....ឆ្នាំ.....

ភាគី ក	ភាគី ខ
នាយខណ្ឌរដ្ឋបាលជលផលកោះកុង	**ប្រធានគណៈកម្មការសហគមន៍នេសាទ**
ហត្ថលេខា	ហត្ថលេខា

ថ្ងៃទី.....ខែ.....ឆ្នាំ.....

សាក្សី

ឃុំ.....

ហត្ថលេខា

328000
331000
334000
337000
340000
343000
1237000
1234000
1231000
1228000
1225000
N
ព្រលាន
អណ្តូងទឹក
ភូមិ
ក
ណ
ល
ណ
ណ
ណ
ល
ណ
ណ
ល
ណ
ណ
ល

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

បញ្ជីឈ្មោះសមាជិកសហគមន៍នេសាទឃុំកណ្តាល

ល.រ	ឈ្មោះ	ភេទ	អាយុ	ភូមិ	ចំនួនមនុស្សក្នុងគ្រួសារ		ថ្ងៃ ខែ ឆ្នាំ ចូលជាសមាជិក
					សរុប	ស្រី	
1	ហុក បូក	ប្រុស	៦៧	កណ្តាល	៥	២	២៣-១១-២០១០
2	គង់ ចិត្ត	ប្រុស	៣០	កណ្តាល	៥	១	២៣-១១-២០១០
3	ឡឹង យេង	ប្រសុ	៣២	កណ្តាល	៥	២	២៣-១១-២០១០
4	គង់ រ៉ាន់	ស្រី	៣៨	កណ្តាល	៦	២	២៣-១១-២០១០
5	សាំង ម៉ែត	ស្រី	៦៤	កណ្តាល	២	១	២៣-១១-២០១០
6	យិន លេន	ប្រុស	៤៩	កណ្តាល	៥	៣	២៣-១១-២០១០
7	គឹម សេង	ស្រី	៥៥	កណ្តាល	៥	៣	២៣-១១-២០១០
8	លាន មេង	ប្រុស	៥០	កណ្តាល	៦	៤	២៣-១១-២០១០
9	ព្រំ ឈឿន	ប្រុស	៦១	កណ្តាល	៧	៣	២៣-១១-២០១០
10	គឹម គុន	ស្រី	៣២	កណ្តាល	៥	៤	២៣-១១-២០១០
11	កែវ ខ្ចៅ	ប្រុស	៦៥	កណ្តាល	២	១	២៣-១១-២០១០
12	កៅ ឡាន់	ស្រី	៥២	កណ្តាល	៥	២	២៣-១១-២០១០
13	យិន សុង	ប្រុស	៣០	កណ្តាល	៥	២	២៣-១១-២០១០
14	គង់ រុច	ស្រី	៣០	កណ្តាល	៨	៤	២៣-១១-២០១០
15	សោម គង់	ប្រុស	៦៥	កណ្តាល	២	១	២៣-១១-២០១០
16	ងួន រ៉ែត	ស្រី	៦៨	កណ្តាល	១	១	២៣-១១-២០១០
17	ហេ្ស៊ប ណាំ	ស្រី	៦២	កណ្តាល	១	១	២៣-១១-២០១០
18	អែត ពោ	ប្រុស	៦៥	កណ្តាល	២	១	២៣-១១-២០១០
19	សេង ចិន	ស្រី	៣៥	កណ្តាល	៨	៤	២៣-១១-២០១០
20	ខ្ចៅ ឈាង	ប្រុស	៤២	កណ្តាល	៥	២	២៣-១១-២០១០
21	ខ្ចៅ ឆែ	ស្រី	៤១	កណ្តាល	៥	៣	២៣-១១-២០១០
22	ឆយ ដាត់	ស្រី	៣៧	កណ្តាល	៨	៥	២៣-១១-២០១០

23	ធូ ឡាត់	ស្រី	៤៥	កណ្តាល	៨	៣	២៣-១១-២០១០
24	កង ធូ	ប្រុស	៨១	កណ្តាល	៤	៣	២៣-១១-២០១០
25	ឡឹង ចាន់ថា	ប្រុស	២៥	កណ្តាល	៣	១	២៣-១១-២០១០
26	ឡឹង កៅ	ប្រុស	៣០	កណ្តាល	៤	២	២៣-១១-២០១០
27	ហៀប គឹម	ប្រុស	៨១	កណ្តាល	១០	៦	២៣-១១-២០១០
28	ហេង នាង	ប្រុស	៤៦	កណ្តាល	៨	៦	២៣-១១-២០១០
29	គឹម រីន	ស្រ	៤៤	កណ្តាល	៧	៤	២៣-១១-២០១០
30	ហៀប ខ្ចៅ	ស្រី	៦៤	កណ្តាល	៨	៤	២៣-១១-២០១០
31	ព្រំ ផល	ស្រី	៣៥	កណ្តាល	៦	៣	២៣-១១-២០១០
32	ជាយ ឆិន	ប្រុស	៤៨	កណ្តាល	៦	៣	២៣-១១-២០១០
33	ណង់ ធឿន	ស្រី	៤០	កណ្តាល	៨	៤	២៣-១១-២០១០
34	សុខ សាំ	ប្រុស	៤២	កណ្តាល	៥	២	២៣-១១-២០១០
35	ព្រំ រិន	ប្រុស	៤២	កណ្តាល	៦	៣	២៣-១១-២០១០
36	យិន ធោ	ប្រុស	៥០	កណ្តាល	៥	៣	២៣-១១-២០១០
37	ហេង រ៉ឿន	ស្រី	៣៥	កណ្តាល	៧	៤	២៣-១១-២០១០
38	ហៀង ហេង	ប្រុស	៣៦	កណ្តាល	៦	៣	២៣-១១-២០១០
39	អ្រ៉ង ចាន់	ប្រុស	៤៨	កណ្តាល	៥	៣	២៣-១១-២០១០
40	ផារ៉ា សុភាព	ប្រុស	១៨	កណ្តាល	៥	៣	២៣-១១-២០១០
41	ឈឹម សាផាន	ប្រុស	៥៥	កណ្តាល	៣	៣	២៣-១១-២០១០
42	ស្យ៉ង ប៉ុល	ប្រុស	៣៥	កណ្តាល	៤	២	២៣-១១-២០១០
43	ចាន់ សំអូន	ប្រុស	៤៥	កណ្តាល	៥	៣	២៣-១១-២០១០
44	ថន រ៉ៃញ	ស្រី	៤៩	កណ្តាល	៥	២	២៣-១១-២០១០
45	ហេង ស៊ីម	ប្រុស	៥៥	កណ្តាល	៦	១	២៣-១១-២០១០
46	ព្រំ សូស	ប្រុស	៤៧	កណ្តាល	៥	៣	២៣-១១-២០១០
47	ភោគ ហ៊ាំ	ស្រី	២៧	កណ្តាល	៥	២	២៣-១១-២០១០
48	ជ ឃួន	ប្រុស	៤៦	កណ្តាល	៥	៣	២៣-១១-២០១០
49	ប៉ុក ហ៊ីម	ប្រុស	៤៧	កណ្តាល	៧	៤	២៣-១១-២០១០
50	ហេង តេង	ប្រុស	៤១	កណ្តាល	៧	៣	២៣-១១-២០១០
51	ឆង់ ទ្រា	ប្រុស	២៧	កណ្តាល	៥	៣	២៣-១១-២០១០

52	ខាន់ ទីត	ប្រុស	២៦	កណ្តាល	៤	៣	២៣-១១-២០១០
53	ហេង ផុន	ប្រុស	៤៥	កណ្តាល	៨	៣	២៣-១១-២០១០
54	ឈឹង តាប់	ប្រុស	៤៦	កណ្តាល	៥	៤	២៣-១១-២០១០
55	ធូ លី	ស្រី	៣៨	កណ្តាល	៩	៣	២៣-១១-២០១០
56	ដាំ យ៉ឿន	ស្រី	៤៦	កណ្តាល	៦	៣	២៣-១១-២០១០
57	ជា ម៉ុន	ស្រី	៦៣	កណ្តាល	៤	២	២៣-១១-២០១០
58	ឆាយ ឡាយ	ប្រុស	៥១	កណ្តាល	៧	៥	២៣-១១-២០១០
59	តេង កាន	ស្រី	៤៦	កណ្តាល	២	១	២៣-១១-២០១០
60	កើត តេង	ប្រុស	៦៦	កណ្តាល	៣	២	២៣-១១-២០១០
61	តេង គាវ	ស្រី	៤៤	កណ្តាល	៧	៤	២៣-១១-២០១០
62	តេង ឡឿន	ប្រុស	៣១	កណ្តាល	២	១	២៣-១១-២០១០
63	ឌី នូ	ប្រុស	២២	កណ្តាល	២	១	២៣-១១-២០១០
64	អ៊ី ជូង	ប្រុស	៤៩	កណ្តាល	៧	៤	២៣-១១-២០១០
65	ផាត់ ទី	ប្រុស	៤៥	កណ្តាល	៦	២	២៣-១១-២០១០
66	ធូ មុត	ប្រុស	២៥	កណ្តាល	៤	២	២៣-១១-២០១០
67	មាស សុវណ្ណ	ប្រុស	៣៤	កណ្តាល	៤	១	២៣-១១-២០១០
68	ស៊ ស៊ីរ៉ាត់	ប្រុស		កណ្តាល	៥	២	២៣-១១-២០១០
69	ហេង ផាន	ប្រុស	៤៣	កណ្តាល	៥	៣	២៣-១១-២០១០
70	ខ្ចៅ ធ្ងឿន	ប្រុស	៣៥	កណ្តាល	៧	៦	២៣-១១-២០១០
71	ចិក ឆាវ	ស្រី	២៧	កណ្តាល	៥	៤	២៣-១១-២០១០
72	ហេង គន្ធា	ស្រី	២៣	កណ្តាល	៤	២	២៣-១១-២០១០
73	ណង់ ធី	ស្រី	៣៥	កណ្តាល	៤	៣	២៣-១១-២០១០
74	គង់ ជុំ	ប្រុស	៤៣	កណ្តាល	៨	៤	២៣-១១-២០១០
75	ស៊ ធួន	ប្រុស	៥៦	កណ្តាល	៣	១	២៣-១១-២០១០
76	ហុក ភូ	ប្រុស	៧៣	កណ្តាល	២	១	២៣-១១-២០១០
77	ជា ឆាន់	ប្រុស	៤៣	កណ្តាល	៦	៣	២៣-១១-២០១០
78	ម៉ាក់ ជ្ងឿន	ស្រី	២៧	ប្រលាន	៥	៤	២៣-១១-២០១០
79	ទន់ ស៊ីម	ស្រី	៣៧	ប្រលាន	២	១	២៣-១១-២០១០
80	ឈឹម លី	ប្រុស	៣៨	ប្រលាន	៥	២	២៣-១១-២០១០

81	មាសរី	ប្រុស	៤៩	ប្រលាន	៦	៤	២៣-១១-២០១០
82	កៅ ខុន	ស្រី		ប្រលាន	៤	២	២៣-១១-២០១០
83	អាន អ្ងក	ប្រុស	៣៩	ប្រលាន	៥	៣	២៣-១១-២០១០
84	រ៉ន លីម	ប្រុស	២៦	ប្រលាន	៤	១	២៣-១១-២០១០
85	ចិន សុភ័ក្ត	ប្រុស	២៥	ប្រលាន	៤	២	២៣-១១-២០១០
86	តើត ខេន	ប្រុស	២៧	ប្រលាន	៤	២	២៣-១១-២០១០
87	ម៉ាក់ រឿន	ស្រី	២៦	ប្រលាន	៤	១	២៣-១១-២០១០
88	ឆោម រ៉ាន	ប្រុស	៤៤	ប្រលាន	៦	៣	២៣-១១-២០១០
89	សំ ម៉ាក	ប្រុស	៦២	ប្រលាន	២	១	២៣-១១-២០១០
90	ង៉ែត ង៉ែត	ស្រី		ប្រលាន	២	១	២៣-១១-២០១០
91	ម៉ាក់ រ៉ូន	ស្រី	២៣	ប្រលាន	៦	២	២៣-១១-២០១០
92	ផន សៅរ៉	ប្រុស	៣៦	ប្រលាន	៦	២	២៣-១១-២០១០
93	ពិត តូច	ប្រុស	៣៩	ប្រលាន	៦	៤	២៣-១១-២០១០
94	ប៉ុក សារឿន	ស្រី	៤៧	ប្រលាន	៥	២	២៣-១១-២០១០
95	ឡុង ម្ឿន	ស្រី	៣១	ប្រលាន	៧	៣	២៣-១១-២០១០
96	ឃុន ង៉ៅ	ស្រី	២៩	ប្រលាន	៤	២	២៣-១១-២០១០
97	ឡុងរ៉	ប្រុស	២២	ប្រលាន	៣	១	២៣-១១-២០១០
98	ហ៊ោ សន	ស្រី		ប្រលាន	១	១	២៣-១១-២០១០
99	លី ហ្ស៊ីវ	ប្រុស		ប្រលាន	៣	១	២៣-១១-២០១០
100	ហ៊ង ហ្ស៊ីង	ស្រី	៥០	ប្រលាន	៨	៤	២៣-១១-២០១០
101	ម៉ាន ចិន	ស្រី	២២	ប្រលាន	៤	៣	២៣-១១-២០១០
102	ណាត់ ខន	ស្រី	៣០	ប្រលាន	៦	៤	២៣-១១-២០១០
103	ប៊ុន ណា	ស្រី	២៤	ប្រលាន	២	១	២៣-១១-២០១០
104	យ៉ិន ហុង	ប្រុស	៤៤	ប្រលាន	៣	១	២៣-១១-២០១០
105	រ៉ែត ឆាត់	ស្រី	២២	ប្រលាន	៣	១	២៣-១១-២០១០
106	ម្ឿន ហ្ស៊ីត	ស្រី	២២	ប្រលាន	៣	២	២៣-១១-២០១០
107	ស៊ូន សារ៉ែត	ប្រុស	៤៩	ប្រលាន	៤	២	២៣-១១-២០១០
108	យ៉ូត ស្ម្ឿន	ប្រុស	៣៣	ប្រលាន	៥	៣	២៣-១១-២០១០
109	ហ៊ង លី	ស្រី	៤៨	ប្រលាន	៨	៥	២៣-១១-២០១០

110	មាស ណាត់	ប្រុស	៦១	ប្រលាន	២	១	២៣-១១-២០១០
111	ឃុន ឈេង	ប្រុស	៤១	ប្រលាន	៧	៣	២៣-១១-២០១០
112	ហួន រ៉ន	ស្រី	២០	ប្រលាន	៥	៤	២៣-១១-២០១០
113	លីម ណាង	ស្រី	៤២	ប្រលាន	២	១	២៣-១១-២០១០
114	ញ៉ ផាន	ស្រី	៥៤	ប្រលាន	៥	២	២៣-១១-២០១០
115	ព្រំ រឿន	ស្រី	៥២	ប្រលាន	៨	៥	២៣-១១-២០១០
116	ម្សៀង យ៉ាន់	ស្រី	៥៤	ប្រលាន	៥	១	២៣-១១-២០១០
117	ទិត្យ រ៉ាត	ស្រី	៤២	ប្រលាន	១០	៤	២៣-១១-២០១០
118	សេង ស៊ូ	ស្រី	៣០	ប្រលាន	៤	៣	២៣-១១-២០១០
119	សំ មន	ស្រី	៤៣	ប្រលាន	៥	៣	២៣-១១-២០១០
120	ហេ ហ៊ូ	ស្រី	២៥	ប្រលាន	៧	៤	២៣-១១-២០១០
121	អ៊ិន មុំ	ស្រី	២៧	ប្រលាន	៤	២	២៣-១១-២០១០
122	សន ស៊ុយ	ស្រី	៤៨	ប្រលាន	៤	៣	២៣-១១-២០១០
123	កែវ សយស	ស្រី	៦៤	ប្រលាន	៥	២	២៣-១១-២០១០
124	សំ ដារ៉ា	ប្រុស	៣៥	ប្រលាន	៤	២	២៣-១១-២០១០
125	លិន ម៉ូយ	ស្រី	៤២	ប្រលាន	៨	៧	២៣-១១-២០១០
126	គេង ចាន់	ស្រី	៣៦	ប្រលាន	៥	២	២៣-១១-២០១០
127	ឆេង ហ៊ែត	ស្រី	៣៥	ប្រលាន	៦	៤	២៣-១១-២០១០
128	ហ្សៀង ភឿន	ស្រី	៣២	ប្រលាន	៤	២	២៣-១១-២០១០
129	ហេ រ៉ុន	ស្រី	៣១	ប្រលាន	៤	២	២៣-១១-២០១០
130	ហេ ភ្ជុំ	ស្រី	២០	ប្រលាន	៦	៣	២៣-១១-២០១០
131	ព្រំ ឡុង	ស្រី	៣៥	ប្រលាន	៤	២	២៣-១១-២០១០
132	ហេ ខា	ស្រី	២១	ប្រលាន	២	១	២៣-១១-២០១០
133	យិន ហុន	ស្រី	៣៣	ប្រលាន	៤	២	២៣-១១-២០១០
134	ឈុំ អាន់	ស្រី	៤១	ប្រលាន	៣	៣	២៣-១១-២០១០
135	ឆន រុន	ស្រី	៥៣	ប្រលាន	៤	៤	២៣-១១-២០១០
136	អ៊ិន ង៉ែត	ប្រុស	២៥	ប្រលាន	៣	២	២៣-១១-២០១០
137	លី មុំ	ស្រី	២៥	ប្រលាន	៣	២	២៣-១១-២០១០
138	ហេ រ៉ុង	ស្រី	២៦	ប្រលាន	៤	១	២៣-១១-២០១០

139	លិន លី	ប្រុស	៥០	ប្រលាន	៤	៣	២៣-១១-២០១០
140	សារ៉ាយ រ៉ឿន	ប្រុស	៣១	ប្រលាន	៤	២	២៣-១១-២០១០
141	ឡុង សីម	ប្រុស	៥០	ប្រលាន	៨	៤	២៣-១១-២០១០
142	ឈួន ភឿន	ស្រី	២៦	ប្រលាន	៥	៣	២៣-១១-២០១០
143	សាត យ៉ា	ស្រី	៥៣	ប្រលាន	៧	៣	២៣-១១-២០១០
144	ឆេង ហាន	ស្រី	៤១	ប្រលាន	៥	៣	២៣-១១-២០១០
145	ខិន មុំ	ស្រី	១៩	ប្រលាន	៣	១	២៣-១១-២០១០
146	មាស ធឿន	ស្រី	៥០	ប្រលាន	៤	២	២៣-១១-២០១០
147	ស៊ុន យុយ	ស្រី	២៧	ប្រលាន	៣	១	២៣-១១-២០១០
148	ស៊ុន យ៉ឿន	ស្រី	២៤	ប្រលាន	៤	២	២៣-១១-២០១០
149	ហ៊ឿង ហ្សែន	ស្រី	៣៩	ប្រលាន	៦	៤	២៣-១១-២០១០
150	ហួន ហាន់	ប្រុស	៣០	ប្រលាន	៦	៣	២៣-១១-២០១០
151	មឿន គួន	ប្រុស	២៥	ប្រលាន	៣	១	២៣-១១-២០១០
152	នន មុំ	ស្រី	២៣	ប្រលាន	៤	២	២៣-១១-២០១០
153	ផុង បិន	ប្រុស	២១	ប្រលាន	៣	១	២៣-១១-២០១០
154	ធឿន ភា	ប្រុស	២៥	ប្រលាន	៤	២	២៣-១១-២០១០
155	លី ញ៉ាញ់	ប្រុស	២២	ប្រលាន	៣	២	២៣-១១-២០១០
156	ហេង ហាក់	ប្រុស	២៩	ប្រលាន	៥	៣	២៣-១១-២០១០
157	ហេង បូ	ប្រុស	៥៥	ប្រលាន	៥	៤	២៣-១១-២០១០
158	លិ ចិង	ប្រុស	២៧	ប្រលាន	៤	១	២៣-១១-២០១០
159	សៀង ប្រុញ	ប្រុស	២៩	ប្រលាន	៤	៣	២៣-១១-២០១០
160	អ៊ិន ម៉ែ	ប្រុស	២៩	ប្រលាន	៥	១	២៣-១១-២០១០
161	ហ្សែង យង់	ប្រុស	៣៨	ប្រលាន	៥	២	២៣-១១-២០១០
162	សារ៉ាយ រ៉ឿន	ប្រុស	៣១	ប្រលាន	៤	២	២៣-១១-២០១០
163	ឈួន រ៉ែត	ប្រុស	៣១	ប្រលាន	៥	២	២៣-១១-២០១០
164	ណាន ពៅ	ស្រី	២៩	ប្រលាន	៤	២	២៣-១១-២០១០
165	ណាន់ ហ៊ាំ	ស្រី	៥០	ធ្ងន់	៩	៣	២៣-១១-២០១០
166	សៅ សៀន	ស្រី	៥០	ធ្ងន់	៣	១	២៣-១១-២០១០
167	ហង់ ថា	ប្រុស	២៩	ធ្ងន់	៥	៤	២៣-១១-២០១០

168	សាក់ ទី	ប្រុស	៤២	ធ្ងន់	៦	៤	២៣-១១-២០១០
169	យិន ណេង	ស្រី	៤៤	ធ្ងន់	៩	៥	២៣-១១-២០១០
170	សៃ ហុង	ប្រុស	៥២	ធ្ងន់	៤	២	២៣-១១-២០១០
171	យ៉ូ រ៉ូនវ៉ែន	ស្រី	៥៧	ធ្ងន់	៨	៤	២៣-១១-២០១០
172	យ្យ៉ាន យីន	ប្រុស	២៩	ធ្ងន់	៥	២	២៣-១១-២០១០
173	កាន់ មូល	ប្រុស	៥០	ធ្ងន់	៩	៥	២៣-១១-២០១០
174	ហេង រ៉ាន់	ស្រី	២៥	ធ្ងន់	៣	១	២៣-១១-២០១០
175	ព្រ ធេង	ប្រុស	១៩	ធ្ងន់	៧	៤	២៣-១១-២០១០
176	ព្រ ឌីន	ប្រុស	៤៥	ធ្ងន់	៨	៣	២៣-១១-២០១០
177	យិន ប៉ុក	ប្រុស	៦៩	ធ្ងន់	៣	២	២៣-១១-២០១០
178	លិន ឃួន	ប្រុស	៣៥	ធ្ងន់	៦	៤	២៣-១១-២០១០
179	ហួន យ៉ន	ស្រី	២៦	ធ្ងន់	៤	២	២៣-១១-២០១០
180	ឆាវ ធេង	ប្រុស	២៩	ធ្ងន់	៤	១	២៣-១១-២០១០
181	ឡាត់ ប៉ែត	ប្រុស	២៣	ធ្ងន់	៣	១	២៣-១១-២០១០
182	សំ ហាន់	ប្រុស	៥៥	ធ្ងន់	៣		២៣-១១-២០១០
183	សំ ហួន	ស្រី	៤៨	ធ្ងន់	៨	៤	២៣-១១-២០១០
184	សេង ម៉ុំ	ស្រី	៤២	ធ្ងន់	៤	៣	២៣-១១-២០១០
185	ព្រ ឈេង	ប្រុស	៥៣	ធ្ងន់	៧	៣	២៣-១១-២០១០
186	រិត ធឿន	ប្រុស	៤៣	ធ្ងន់	៤	២	២៣-១១-២០១០
187	សឹង ធី	ស្រី	៣១	ធ្ងន់	២	១	២៣-១១-២០១០
188	ឈឹម ផន	ស្រី	២៩	ធ្ងន់	៥	២	២៣-១១-២០១០
189	សាំង ស្រី	ស្រី	៥៥	ធ្ងន់	៣	៣	២៣-១១-២០១០
190	ប្រ៊ីង គី	ស្រី	៣១	ធ្ងន់	៥	៤	២៣-១១-២០១០
191	ពុត គីម	ស្រី	៣៨	ធ្ងន់	៥	២	២៣-១១-២០១០
192	ព្រ រ៉	ស្រី	៤៦	ធ្ងន់	៧	៣	២៣-១១-២០១០
193	ឡ្ស៊ីង ណៃ	ស្រី	៣៩	ធ្ងន់	៥	៤	២៣-១១-២០១០
194	ព្រ ហួន	ប្រុស	៥៥	ធ្ងន់	៤	៣	២៣-១១-២០១០
195	យ៉ីង លីន	ស្រី	៥៣	ធ្ងន់	៥	៣	២៣-១១-២០១០
196	ហួន ហេង	ប្រុស	២៩	ធ្ងន់	៤	១	២៣-១១-២០១០

197	ហុង ឆុ	ស្រី	២៥	ធ្ងន់	៤	២	២៣-១១-២០១០
198	គង់ ឡាន់	ស្រី	៤៥	ធ្ងន់	៧	៦	២៣-១១-២០១០
199	ណាន់ ឌឿន	ប្រុស	២៥	ធ្ងន់	៥	២	២៣-១១-២០១០
200	ហុង រិត	ប្រុស	២៤	ធ្ងន់	៦	៣	២៣-១១-២០១០
201	យិន តុំ	ប្រុស	២៣	ធ្ងន់	៦	៣	២៣-១១-២០១០
202	ណាន់ ឈួន	ប្រុស	២៥	ធ្ងន់	៤	២	២៣-១១-២០១០
203	សុខ ខន	ស្រី	៥២	ធ្ងន់	៥	២	២៣-១១-២០១០
204	សៃ ហុង	ប្រុស	៥២	ធ្ងន់	៤	២	២៣-១១-២០១០
205	ហឿន ហុង	ប្រុស	៥១	ធ្ងន់	៥	៣	២៣-១១-២០១០
206	យិន មេន	ស្រី	៦១	ធ្ងន់	២	១	២៣-១១-២០១០
207	យិន ប៊ុក	ប្រុស	៦៧	ធ្ងន់	៣	២	២៣-១១-២០១០
208	ព្រុំ ហ៊ីម	ប្រុស	៧៩	ធ្ងន់	២	១	២៣-១១-២០១០
209	អេវ ហេង	ប្រុស	៦៦	ធ្ងន់	៦	៤	២៣-១១-២០១០
210	ហឿង ហាត់	ប្រុស	៤៤	ធ្ងន់	៩	៣	២៣-១១-២០១០
211	ហាន់ ណៃ	ស្រី	៤៥	ធ្ងន់	១០	៣	២៣-១១-២០១០
212	ហឿង ហៃ	ប្រុស	៤២	ធ្ងន់	៧	២	២៣-១១-២០១០
213	សុខ សិន	ប្រុស	៤២	ធ្ងន់	៦	២	២៣-១១-២០១០
214	ហួន ហេង	ប្រុស	២៣	ធ្ងន់	៤	១	២៣-១១-២០១០
215	រ៉ី រ៉ានានីន	ប្រុស	២៤	ធ្ងន់	៤	២	២៣-១១-២០១០
216	គង យិន	ប្រុស	៦៥	ធ្ងន់	៦	២	២៣-១១-២០១០
217	ម៉ែ រ៉ាំ	ស្រី	៤៥	ធ្ងន់	៧	៣	២៣-១១-២០១០
218	ហឿង ហេ	ប្រុស	៣៤	ធ្ងន់	៧	៤	២៣-១១-២០១០
219	ភោ ភាព	ប្រុស	២៤	ធ្ងន់	៤	២	២៣-១១-២០១០
220	សុខ ផេន	ស្រី	៤២	ធ្ងន់	៤	២	២៣-១១-២០១០
221	អន់ ឡា	ប្រុស	៣៤	ធ្ងន់	៥	៣	២៣-១១-២០១០
222	យី ជាតិ	ប្រុស	៣៣	ធ្ងន់	៤	១	២៣-១១-២០១០
223	ញ៉ូ សីទូន	ស្រី	២០	ធ្ងន់	៣	២	២៣-១១-២០១០
224	សាន់ ឆាន់	ស្រី	២៦	ធ្ងន់	៣	២	២៣-១១-២០១០
225	ហ៊ីម ឌាង	ប្រុស	៥៣	ធ្ងន់	៥	២	២៣-១១-២០១០

226	ហ្ស៊ីង ហាំ	ស្រី	៣៩	ធ្ងង់	៦	៣	២៣-១១-២០១០
227	កែវ ចាន់	ស្រី	២០	ធ្ងង់	៣	២	២៣-១១-២០១០
228	ហាន់ ឡាយ	ស្រី	៥៣	ធ្ងង់			២៣-១១-២០១០
229	គាន រ៉ាន	ស្រី	៥០	ធ្ងង់	៧	៥	២៣-១១-២០១០
230	សាន កេង	ស្រី	២៣	ធ្ងង់	៥	៣	២៣-១១-២០១០
231	ឌុយ ធ្យៀ	ប្រុស	៥៤	ធ្ងង់	៧	៣	២៣-១១-២០១០
232	អ៊ុក ស្ងឿន	ប្រុស	៥២	ធ្ងង់	៨	៣	២៣-១១-២០១០
233	សាន់ គុយ	ប្រុស	២៥	ធ្ងង់	៤	២	២៣-១១-២០១០
234	សិង ម៉ៅ	ស្រី	២១	ធ្ងង់	៤	១	២៣-១១-២០១០
235	ហ៊ីម ហាន់	ស្រី	៥២	ធ្ងង់	៤	២	២៣-១១-២០១០
236	លី សេង	ប្រុស	៣១	ធ្ងង់	៤	២	២៣-១១-២០១០
237	អ៊ុក ធ្ងឿន	ប្រុស	៤៩	ធ្ងង់	៤	២	២៣-១១-២០១០
238	អ្ងឿ រ៉ាន់	ប្រុស	៤៥	ធ្ងង់	៥	៣	២៣-១១-២០១០
239	ហេង ហួន	ប្រុស	៤៥	ធ្ងង់	១១	៤	២៣-១១-២០១០
240	ប្រ៊ីង ទូរ	ប្រុស	៣២	ធ្ងង់	៤	២	២៣-១១-២០១០
241	ហង់ ហ្ស៊ីន	ប្រុស	៤៤	ធ្ងង់	៨	៥	២៣-១១-២០១០
242	ហ៊ុន សុខន	ស្រី	៤០	ធ្ងង់	៥	២	២៣-១១-២០១០
	សរុប				**១១៥៧**	**៦១៧**	២៣-១១-២០១០

ស្មើ ១១២ នាក់
ស្ត្រី ១០ នាក់

កណ្តាល , ថ្ងៃទី..ណ.ខ.....ខែ....ធ្នូ.....ឆ្នាំ ២០១០
ប្រធានគណៈកម្មការសហគមន៍នេសាទ

ណាង ហ្ស

លេខ..២១២/២០១០ សហគ

ប្រជាជនចំនួន ២៤២ នាក់ ស្រីចំនួន ៦១៧ នាក់ រស់នៅភូមិ ប្រលាន ភូមិធ្ងង់ និងភូមិកណ្តាល ពិតជាបានចុះឈ្មោះចូលជាសមាជិកសហគមន៍នេសាទឃុំកណ្តាល ពិតប្រាកដមែន ។

កណ្តាល , ថ្ងៃទី..ណ.ខ....ធ្នូ.....ឆ្នាំ ២០១០

មេឃុំកណ្តាល

ស្ត្រីង ~ ស្ត្រី

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

បញ្ជីឈ្មោះគណៈកម្មការសហគមន៍នេសាទឃុំកណ្តាល

ឃុំកណ្តាល ស្រុកបូទុមសាគរ ខេត្តកោះកុង

ល.រ	ឈ្មោះ	ភេទ	អាយុ	ភូមិ	តួនាទីគណៈកម្មការ
១	ហេង ហួន	ប្រុស		ផ្ទះ	ប្រធានគណៈកម្មការសហគមន៍នេសាទ
២	ស៊ីង ប៉ះ	ស្រី		ផ្ទះ	អនុប្រធានទី ១
៣	វ៉ា យ៉ែត	ប្រុស		ផ្ទះ	អនុប្រធានទី ២
៤	ឈឹម សាផាន	ប្រុស		កណ្តាល	សមាជិក
៥	ឈុយ រ៉ី	ប្រុស		កណ្តាល	សមាជិក
៦	គេង ឈិ	ស្រី		កណ្តាល	សមាជិក
៧	ហ្ស៊ីង ហាត់	ប្រុស		ផ្ទះ	សមាជិក

ធ្វើនៅកណ្តាល , ថ្ងៃទី.២០.ខែ...ធ្នូ.....ឆ្នាំ ២០១០

ប្រធានគណៈកម្មការសហគមន៍នេសាទ

ហេង ហួន

បានឃើញ និង បញ្ជាក់ថា

ឈ្មោះនៅក្នុងបញ្ជីខាងលើនេះ គឺជាសមាជិកគណៈកម្មការ

សហគមន៍នេសាទឃុំកណ្តាល ពិតប្រាកដមែន ។

ធ្វើនៅកណ្តាល , ថ្ងៃទី.២១..ខែ....ធ្នូ.....ឆ្នាំ ២០១០

មេឃុំកណ្តាល

ស៊ីង ភ្ជ

តារាងខ្ញុបសម្ព័ន្ធ

ក-រចនាសម្ព័ន្ធសហគមន៍នេសាទឃុំកណ្តាល

ខ-តួនាទី និងភារកិច្ចនិងទួលខុសត្រូវរបស់គណៈកម្មការសហគមន៍នេសាទ

១-ប្រធានគណៈកម្មការសហគមន៍នេសាទ

-ដឹកនាំ និងទទួលខុសត្រូវរួមក្នុងការអនុវត្តន៍ការងារនៅក្នុងសហគមន៍នេសាទ

-សម្របសម្រួលការងារជាមួយស្ថាប័នជំនាញ និងអាជ្ញាធរមូលដ្ឋាន ដើម្បីគាំទ្រដល់ការងារសហគមន៍

-ទំនាក់ទំនងជាមួយអង្គការនានា ដើម្បីស្វែងរកជំនួយទ្រទ្រង់សកម្មភាពសហគមន៍នេសាទ

-សម្របសម្រួលដោះស្រាយបញ្ហាផ្សេងៗក្នុងសហគមន៍នេសាទ

-តាមដានត្រួតពិនិត្យរាល់សកម្មភាពការងាររបស់សហគមន៍នេសាទ

-ដឹកនាំរាល់ការប្រជុំ និងមហាសន្និបាតក្នុងការបូកសរុបវាយតម្លៃ និងរៀបចំផែនការការងារ

-ផ្តល់ភាពយុត្តិធម៌ និងតម្លាភាពដល់សមាជិកសហគមន៍ ។

២-អនុប្រធានទី១ ទទួលបន្ទុករដ្ឋបាល និងហិរញ្ញវត្ថុ

-ចូលរួមអនុវត្តការងារជាមួយប្រធាន

-ជំនួសមុខឱ្យប្រធាន នៅពេលអវត្តមាន

-ទទួលការកិច្ចផ្សេងៗ ដែលប្រធានប្រគល់ជូន ។

-កត់ត្រារាល់សកម្មភាព និងរក្សាទុកដាក់ឯកសារផ្សេងៗ របស់សហគមន៍

-ធ្វើកំណត់ហេតុរាល់ការប្រជុំ និងមហាសន្និបាតរបស់សហគមន៍នេសាទ

-រៀបចំលិខិតអញ្ជើញ និងទីកន្លែងប្រជុំ

-ទទួលពាក្យស្នើសុំចូលជាសមាជិក និងលាលែងពីសមាជិក

-កត់ត្រា និងគ្រប់គ្រងសម្ភារៈរបស់សហគមន៍នេសាទ

-រៀបចំបែបបទ និងលិខិតស្នាមផ្សេងៗ ដែលទាក់ទងការគ្រប់គ្រងសហគមន៍

-ទទួលពាក្យបណ្តឹងតវ៉ាផ្សេងៗ

-ព្រាងរបាយការណ៍ពីលទ្ធផលការងាររបស់សហគមន៍នេសាទ ដើម្បីដាក់ជូនប្រធានពិនិត្យ និងសម្រេច ។

-ទទួលខុសត្រូវការងារហិរញ្ញវត្ថុរបស់សហគមន៍នេសាទទាំងមូល

-គ្រប់គ្រង និងចុះបញ្ជីគណនេយ្យរបស់សហគមន៍នេសាទ ឱ្យបានត្រឹមត្រូវតាមប្រព័ន្ធការងារគណនេយ្យ

-ស្នើសុំការឯកភាពពីសមាជិកគណៈកម្មការសហគមន៍នេសាទ នូវរាល់ចំណាយផ្សេងៗ និងរក្សាទុកឯកសារឱ្យ
  បានត្រឹមត្រូវ

-រៀបចំបែបបទ និងទទួលប្រាក់សមាជិកភាព និងភាគទានប្រចាំឆ្នាំពីសមាជិក ។

៣-អនុប្រធានទី២ ទទួលបន្ទុកត្រួតពិនិត្យ យាមល្បាត និងសម្របសម្រួល

-ទទួលខុសត្រូវលើកិច្ចការការពារធនធានជលផល និងទប់ស្កាត់បទល្មើស ដែលកើតមានក្នុងដែននេសាទ
  សហគមន៍

-ទទួលបន្ទុកពិនិត្យ តាមដាន ឃ្លាំមើល និងល្បាតនូវរាល់សកម្មភាពនេសាទ ។ ករណីចាំបាច់ត្រូវរាយការណ៍
  ព័ត៌មានជូនប្រធានឱ្យបានឆាប់រហ័ស

-សហការជាមួយសមត្ថកិច្ចជលផល បង្ក្រាបរាល់បទល្មើសជលផលនៅក្នុងកន្លែងនេសាទសហគមន៍ ។ ក្នុង
  ករណីបន្ទាន់ និងចាំបាច់ ផ្នែកល្បាតសហគមន៍នេសាទអាចស្នើសុំអន្តរាគមន៍ពីសមត្ថកិច្ចនៅជិតខាង អាជ្ញាធរ
  ដែនដី ដើម្បីឃាត់ ទុកវត្ថុតាងនៃបទល្មើស និងឃាត់ខ្លួនជនល្មើស រួចបញ្ជូនជាបន្ទាន់ទៅសមត្ថកិច្ចជលផល
  ដើម្បីធ្វើការដោះស្រាយបទល្មើសទៅ តាមច្បាប់

-រៀបចំផែនការល្បាត និងចាត់វិធានការការពារធនធានធម្មជាតិក្នុងតំបន់គ្រប់គ្រង ដើម្បីអនុវត្តឱ្យមាន
  ប្រសិទ្ធភាព

-តាមដាន ស្រាវជ្រាវ និងគ្រប់គ្រងអ្នកមិនមែនជាសមាជិកសហគមន៍នេសាទ ដែលចូលធ្វើនេសាទក្នុងកន្លែង
  នេសាទសហគមន៍

-ធ្វើរបាយការណ៍បូកសរុបលទ្ធផលសកម្មភាពការងាររបស់ខ្លួន ជូនប្រធានគណៈកម្មការសហគមន៍នេសាទ រៀងរាល់ខែ ។

៤-សមាជិក ទទួលបន្ទុកផែនការ និងទំនាក់ទំនង

-រៀបចំគម្រោងផែនការប្រើប្រាស់ហិរញ្ញវត្ថុរបស់សហគមន៍ ដើម្បីគណៈកម្មការសហគមន៍នេសាទពិនិត្យ និងសម្រេច

-ធ្វើរបាយការណ៍ និងរាយការណ៍ពីស្ថានភាពចំណូល-ចំណាយ ជូនគណៈកម្មការសហគមន៍ជារៀងរាល់ខែ

៥-សមាជិក ទទួលបន្ទុកវិវាទ និងអប់រំផ្សព្វផ្សាយ

-អប់រំផ្សព្វផ្សាយពីខ្លឹមសារលក្ខន្តិក: បទបញ្ជាផ្ទៃក្នុង ច្បាប់ អនុក្រឹត្យ សេចក្តីជូនដំណឹង និងលិខិតបទដ្ឋាននានា ដែលពាក់ព័ន្ធលើការគ្រប់គ្រងវិស័យជលផល បរិស្ថាន សិទ្ធិមនុស្ស អនាម័យ និងសុខភាព ។ល។ ជូនដល់សមាជិក សហគមន៍របស់ខ្លួន និងសហគមន៍នេសាទជិតខាង

-ស្វែងរកវិធីសាស្ត្រ និងបទពិសោធន៍ល្អៗ សម្រាប់ធ្វើការអប់រំផ្សព្វផ្សាយឱ្យរីតតែមានប្រសិទ្ធភាព

-រៀបចំឯកសារ ស្លាកសញ្ញា និងរូបភាពផ្សេងៗ សម្រាប់ធ្វើការអប់រំផ្សព្វផ្សាយ

-រៀបចំវគ្គបណ្តុះបណ្តាល ទស្សនៈកិច្ចសិក្សា ដើម្បីលើកកម្ពស់ការយល់ដឹង និងផ្លាស់ប្តូរបទពិសោធន៍ ក្នុងការគ្រប់គ្រងធនធានធម្មជាតិ

-ធ្វើរបាយការណ៍ពីលទ្ធផលការអប់រំ និងការវាយតម្លៃផែនការអនុវត្ត ជូនប្រធានគណៈកម្មការសហគមន៍នេសាទរៀងរាល់ខែ ។

ធ្វើនៅ.....ថ្ងៃទី.....ខែ.....ឆ្នាំ ២០..

ប្រធានគណៈកម្មការសហគមន៍នេសាទ

ចេង ហ្ស

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លក្ខន្តិកៈសហគមន៍នេសាទ ឃុំកណ្តាល

ឈ្មោះសហគមន៍នេសាទ	:	ឃុំកណ្តាល
ភូមិ	:	កណ្តាល ប្រលាន ធ្នង់
ឃុំ	:	កណ្តាល
ស្រុក	:	បូទុមសាគរ
ខេត្ត	:	កោះកុង

ជំពូកទី ១

គោលបំណង និងនាមករណ៍

ប្រការ ១

លក្ខន្តិកៈនេះមានគោលបំណង :

-កំណត់ក្របខ័ណ្ឌនៃការគ្រប់គ្រង ការការពារ ការអភិរក្ស ការអភិវឌ្ឍន៍ និងការប្រើប្រាស់ធនធានជលផលរបស់សហគមន៍នេសាទ ប្រកបដោយនិរន្តរភាព ។

-ធ្វើជាគោលការណ៍ត្រឹះ និងជាយន្តការសម្រាប់ដំណើរការសហគមន៍នេសាទ

-ការពារសិទ្ធិ និងផលប្រយោជន៍របស់សមាជិកសហគមន៍នេសាទ និងផលប្រយោជន៍សាធារណៈ ។

ប្រការ ២

ឈ្មោះសហគមន៍នេសាទឃុំកណ្តាល អាស័យដ្ឋានភូមិកណ្តាល ឃុំកណ្តាល ស្រុកបូទុមសាគរ ខេត្តកោះកុង

សហគមន៍នេសាទនេះមានការចូលរួមពីប្រជាពលរដ្ឋដែលរស់ក្នុង :

១-ភូមិ កណ្តាល ឃុំ កណ្តាល ស្រុកបូទុមសាគរ ខេត្តកោះកុង

២-ភូមិប្រលាន ឃុំកណ្តាល ស្រុកបូទុមសាគរ ខេត្តកោះកុង

៣-ភូមិ ផ្ទង់ ឃុំកណ្តាល ស្រុក បូទុមសាគរ ខេត្តកោះកុង

មានកម្មវត្ថុ : បង្កើតសហគមន៍នេសាទ

ជំពូកទី ២

លក្ខខណ្ឌនៃការសុំចូលជាសមាជិក ភាតពួកកិច្ច និងសិទ្ធិរបស់សមាជិក

ប្រការ ៣

ប្រជាពលរដ្ឋទាំងពីរភេទដែលមានបំណងចង់ចូលជាសមាជិកសហគមន៍នេសាទ មានសិទ្ធិដាក់ពាក្យសុំចូលដោយស្ម័គ្រចិត្ត និងត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម :

-មានលំនៅដ្ឋាននៅក្នុងបណ្តាភូមិនៃសហគមន៍នេសាទ

-មានសញ្ជាតិខ្មែរ

-មានអាយុចាប់ពី ១៨ ឆ្នាំឡើង ។

ប្រការ ៤

សមាជិកសហគមន៍នេសាទដែលបានបំពេញលក្ខខណ្ឌក្នុងប្រការ ៣ ខាងលើមានសិទ្ធិ :

-ចូលរួមប្រជុំមហាសន្និបាត និងបោះឆ្នោតស្មើភាពគ្នា

-បោះឆ្នោត និងឈរឈ្មោះជាបេក្ខជននៃគណៈកម្មការសហគមន៍នេសាទ ស្របតាមលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទនេះ

-ទទួលព័ត៌មានអំពីស្ថានភាពសេដ្ឋកិច្ចសង្គមរបស់សហគមន៍នេសាទ ពីគណៈកម្មការសហគមន៍នេសាទ

-ស្នើឱ្យមានការកោះប្រជុំមហាសន្និបាតវិសាមញ្ញ ដើម្បីធ្វើការពិភាក្សា និងសម្រេចលើបញ្ហាណាមួយ បើមានការស្នើសុំពីសមាជិកយ៉ាងតិចមួយភាគបី(១/៣) នៃសមាជិកសហគមន៍នេសាទទាំងអស់

-ធ្វើនេសាទជាលក្ខណៈគ្រួសារស្របតាមច្បាប់ស្តីពីជលផល កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ និងលិខិតបទដ្ឋានគតិយុត្តិនានា ដែលពាក់ព័ន្ធវិស័យជលផល

-ចូលរួមក្នុងសកម្មភាពទាំងអស់របស់សហគមន៍នេសាទ

-ប្តឹងតវ៉ា ឬផ្តល់ព័ត៌មានអំពីបាតុភាពទាំងឡាយ ដែលប៉ះពាល់ដល់ផលប្រយោជន៍របស់សហគមន៍ ទៅសមត្ថកិច្ចរដ្ឋបាលជលផល ក្រុមប្រឹក្សាឃុំ សង្កាត់ អាជ្ញាធរមូលដ្ឋាន និងសមត្ថកិច្ចពាក់ព័ន្ធ

-ទទួលការគាំទ្រពីមជ្ឈដ្ឋានានា ដើម្បីផលប្រយោជន៍របស់សហគមន៍ ។

សមាជិកសហគមន៍នេសាទត្រូវទទួលខុសត្រូវរាល់សកម្មភាពរៀងៗខ្លួន និងរួមគ្នាចំពោះកំហុសដែលខ្លួនបានប្រព្រឹត្តក្នុងពេលបំពេញការកិច្ច ដោយមិនទាន់គិតដល់ការទទួលខុសត្រូវផ្ទៃកព្រហ្មទណ្ឌឡើយ ។

សមាជិកសហគមន៍នេសាទចំនួនមួយភាគដប់(១/១០)ឡើងទៅ អាចស្នើសុំឱ្យប្រធានគណៈកម្មការសហគមន៍នេសាទបញ្ចូលបញ្ហាមួយចំនួន ទៅក្នុងរបៀបវារៈនៃកិច្ចប្រជុំរបស់គណៈកម្មការសហគមន៍នេសាទសាមី ហើយចំនួនសមាជិកសហគមន៍នេសាទដែលបានស្នើសុំខាងលើនេះ អាចចាត់តំណាងចំនួនបី(៣)នាក់ចូលរួមប្រជុំ ដើម្បីចោទសួរគណៈកម្មការសហគមន៍នេសាទនូវបញ្ហាទាំងឡាយណា ដែលទាក់ទងនឹងចំណុចដែលបានស្នើឡើងនោះ ។

ប្រការ ៥

សមាជិកសហគមន៍នេសាទមានកាតព្វកិច្ច និងការកិច្ចដូចខាងក្រោម :

-អនុវត្តតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីជលផល

-អនុវត្តតាមព្រះរាជក្រឹត្យលេខ នស/រកត/០៥០៥/២៤០ ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៥ ស្តីពីការបង្កើតសហគមន៍នេសាទ

-អនុវត្តតាមអនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មិនា ឆ្នាំ ២០០៧ ស្តីពីការគ្រប់គ្រងសហគមន៍នេសាទ និងលិខិតបទដ្ឋានផ្សេងៗទៀត ដែលពាក់ព័ន្ធនឹងសហគមន៍នេសាទ

-អនុវត្តតាមលក្ខន្តិក: បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ កិច្ចព្រមព្រៀង និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

-អនុវត្តតាមសេចក្តីសម្រេចរបស់មហាសន្និបាត និងគណៈកម្មការសហគមន៍នេសាទ

-បង់ប្រាក់សមាជិកភាពចំនួន ៥០០រ (ប្រាំរយរៀលគត់) តាមការសម្រេចរបស់មហាសន្និបាត នៅពេលដែលដាក់ពាក្យសុំចូលជាសមាជិកសហគមន៍នេសាទ

-បង់ប្រាក់វិភាគទានប្រចាំឆ្នាំចំនួន ១.៥០០រ(មួយពាន់ប្រាំរយរៀលគត់) តាមការសម្រេចរបស់មហាសន្និបាត

-ចូលរួមក្នុងសកម្មភាពរបស់សហគមន៍នេសាទ ដើម្បីផលប្រយោជន៍ និងការរីកចំរើនរបស់សហគមន៍នេសាទ

-ចូលរួមការពារ ថែរក្សា និងគ្រប់គ្រងធនធានជលផលក្នុងសហគមន៍នេសាទ

-ចូលរួមឃ្លាំមើល ទប់ស្កាត់ និងរាយការណ៍រាល់សកម្មភាពបទល្មើសជលផលក្នុងកន្លែងនេសាទសហគមន៍

ជំពូកទី ៣

លក្ខណៈវិនិច្ឆ័យ លក្ខខណ្ឌនៃការលាឈប់ និងការបណ្តេញចេញពីសមាជិក

ប្រការ ៦

សមាជិកសហគមន៍នេសាទ មានសិទ្ធិលាឈប់ពីសមាជិកភាពបានដោយ :

-ដាក់ពាក្យសុំលាលែងជាលាយលក្ខណ៍អក្សរ

-ការផ្លាស់ប្តូរទីលំនៅចេញពីកន្លែងនេសាទសហគមន៍

-សាមីខ្លួនទទួលមរណភាព

-សាមីខ្លួនបាត់បង់សម្បទាវិជ្ជាជីវ: ដោយមានលិខិតបញ្ជាក់ពីស្ថាប័នមានសមត្ថកិច្ច ។

ប្រការ ៧

សមាជិកសហគមន៍អាចត្រូវបណ្តេញចេញពីសមាជិកភាព ក្នុងលក្ខខណ្ឌដូចខាងក្រោម :

-ការធ្វើឱ្យប៉ះពាល់ខ្លាំងដល់ផលប្រយោជន៍នៃសហគមន៍នេសាទ ឬសមាជិកសហគមន៍នេសាទដទៃទៀត

-សាមីខ្លួនត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិម

-សាមីខ្លួនបានប្រព្រឹត្តផ្ទុយនឹងលក្ខន្តិក: ឬបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទនេះ ។

ជំពូកទី ៤

របៀបរបបការគ់បញ្ជី និងឯកសារនានា

ប្រការ ៨

ប្រភពហិរញ្ញវត្ថុរបស់សហគមន៍នេសាទបានមកពី :

-វិភាគទានរបស់សមាជិកសហគមន៍នេសាទ

-អំណោយពីសប្បុរសជន

-ជំនួយពីរាជរដ្ឋាភិបាល អង្គការជាតិ និងអង្គការមិនមែនរដ្ឋាភិបាល

-ចំណូលស្របច្បាប់ផ្សេងៗទៀត ។

ប្រការ ៩

រាល់ការចំណាយថវិកា សហគមន៍នេសាទត្រូវអនុវត្តដូចតទៅ :

-ការចំណាយពី ១០០ រៀល ដល់ ២០០.០០០រៀល ត្រូវសម្រេចដោយប្រធានគណៈកម្មការសហគមន៍នេសាទ

-ការចំណាយពី ២០០.០០០ រៀល ដល់ ១.០០០.០០០រៀល ត្រូវសម្រេចដោយគណៈកម្មការសហគមន៍នេសាទ

-ការចំណាយពី ១.០០០.០០០ រៀល ឡើងទៅ ត្រូវសម្រេចដោយមហាសន្និបាត ។

ប្រការ ១០

សហគមន៍នេសាទត្រូវតម្កល់ទុកឯកសារ និងរៀបចំឱ្យមានបញ្ជី :

-ចំណូលចំណាយថវិកា

-សារពើភណ្ឌ

-សមាជិកសហគមន៍នេសាទ

-កំណត់ហេតុប្រជុំមហាសន្និបាតសហគមន៍នេសាទ

-កំណត់ហេតុប្រជុំគណៈកម្មការសហគមន៍នេសាទ

-ឯកសារដទៃទៀតដែលពាក់ព័ន្ធនឹងសហគមន៍នេសាទ ។

ប្រការ ១១

ការគ្រប់គ្រង និងប្រើប្រាស់ថវិកា :

-ការគ្រប់គ្រងថវិកា ត្រូវមានការកាន់បញ្ជីគណនេយ្យ

-ថវិកាចំណូលដែលទទួលបានពីប្រភពផ្សេងៗ ត្រូវរក្សាទុកក្នុងបេឡារបស់សហគមន៍នេសាទ

-រាល់ថវិកាចំណាយ ត្រូវមានរបាយការណ៍ទូទាត់ដោយមានសក្តីប័ត្រ និងចុះបញ្ជីឱ្យបានត្រឹមត្រូវ

-ថវិកាដែលត្រូវចំណាយ គឺសម្រាប់តែបម្រើឱ្យការងារគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍សហគមន៍នេសាទ

ជំពូកទី ៥

គណៈកម្មការសហគមន៍នេសាទ

ប្រការ ១២ រចនាសម្ព័ន្ធសហគមន៍នេសាទឃុំកណ្តាល

ប្រការ ១៣

សមាសភាពគណៈកម្មការសហគមន៍នេសាទរួមមាន ប្រធាន អនុប្រធានទី១ អនុប្រធានទី២ និងសមាជិក។ គណៈកម្មការ សហគមន៍នេសាទ ត្រូវបោះឆ្នោតជ្រើសរើសសមាជិកទទួលបន្ទុកលេខាធិការមួយរូប និងសមាជិកទទួលបន្ទុក ហិរញ្ញិកមួយរូប និងត្រូវពិភាក្សាបែងចែកភារកិច្ចសមាជិកផ្សេងទៀត តាមការជាក់ស្តែង។

ប្រធានគណៈកម្មការសហគមន៍នេសាទទទួលខុសត្រូវដឹកនាំ និងគ្រប់គ្រងសហគមន៍នេសាទទាំងមូល ។

អនុប្រធានគណៈកម្មការសហគមន៍នេសាទ ជាជំនួយការឱ្យប្រធាន ។

ប្រការ ១៤

គណៈកម្មការសហគមន៍នេសាទមានអណ្ណត្តិប្រាំ(៥)ឆ្នាំ ចាប់ពីថ្ងៃបោះឆ្នោត ហើយផុតកំណត់នៅពេលដែលមានគណៈកម្មការសហគមន៍នេសាទថ្មី ដែលត្រូវបានបោះឆ្នោតជ្រើសរើសក្នុងមហាសន្និបាត ឱ្យចូលកាន់តំណែងជំនួស ។ ក្នុងករណីដែលសហគមន៍នេសាទដំណើរការមិនប្រក្រតី ដោយមូលហេតុដំណើរការមិនល្អ ឬអសមត្ថភាពក្នុងការគ្រប់គ្រងសហគមន៍នេសាទ សមាជិកសហគមន៍នេសាទចំនួនពីរភាគបី (២/៣) មានសិទ្ធិស្នើសុំបើកមហាសន្និបាតវិសាមញ្ញ ដើម្បីបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទជាថ្មី ។

ប្រការ ១៥

ក្នុងករណីដែលសមាជិកគណៈកម្មការសហគមន៍នេសាទណាម្នាក់អវត្តមាន ដោយគ្មានមូលហេតុរយៈពេលបី(៣)ខែ ឬសុំលាលែងមុនចប់អណ្ណត្តិ បេក្ខជនដែលមានឈ្មោះតាមសម្លេងគាំទ្របន្ទាប់ក្នុងពេលបោះឆ្នោតជ្រើសរើសក្នុងមហាសន្និបាតកន្លងមក ត្រូវបានជ្រើសតាំងជំនួស ។

ជំពូកទី ៦

របៀបរបបប្រជុំរបស់គណៈកម្មការសហគមន៍នេសាទ

ប្រការ ១៦

គណៈកម្មការសហគមន៍នេសាទ ត្រូវកំណត់របបប្រជុំឱ្យបានទៀងទាត់រៀងរាល់ខែ ។ កិច្ចប្រជុំរបស់គណៈកម្មការសហគមន៍នេសាទអាចប្រព្រឹត្តទៅបាន លុះត្រាតែមានសមាជិកគណៈកម្មការចូលរួមយ៉ាងតិចចំនួនពីរភាគបី(២/៣) នៃសមាជិករបស់គណៈកម្មការសហគមន៍នេសាទទាំងមូល ។

ប្រការ ១៧

ប្រធានគណៈកម្មការសហគមន៍នេសាទជាអ្នកកោះអញ្ជើញ និងធ្វើជាប្រធានគ្រប់កិច្ចប្រជុំ ។ ក្នុងករណីប្រធានគណៈកម្មការសហគមន៍នេសាទអវត្តមាន អនុប្រធានដែលត្រូវបានប្រគល់សិទ្ធិត្រូវធ្វើជាប្រធានអង្គប្រជុំ ។ រាល់ការប្រជុំត្រូវមានកំណត់ហេតុ និងបញ្ជីវត្តមានច្បាស់លាស់ ។

ប្រធានអង្គប្រជុំត្រូវធានាឱ្យគ្រប់កិច្ចប្រជុំសហគមន៍នេសាទ ប្រព្រឹត្តទៅដោយលក្ខណៈប្រជាធិបតេយ្យ មានរបៀបរៀបរយ និងគ្មានការរំខាន ។

ប្រធានអង្គប្រជុំ អាចបណ្តេញចេញសមាជិកអង្គប្រជុំណាម្នាក់ចេញពីកិច្ចប្រជុំបាន ក្នុងករណីសមាជិកនោះធ្វើឱ្យខូចសណ្តាប់ធ្នាប់អង្គប្រជុំ ។

ប្រការ ១៨

ការសម្រេចលើបញ្ហាណាមួយរបស់សហគមន៍ដូចមានចែងខាងក្រោមនេះ គឺត្រូវអនុម័តដោយកិច្ចប្រជុំរបស់គណៈកម្មការសហគមន៍នេសាទ ដោយមានសម្លេងគាំទ្រយ៉ាងតិចលើសពីពាក់កណ្តាលនៃចំនួនសមាជិកគណៈកម្មការសហគមន៍នេសាទដែលមានវត្តមានក្នុងអង្គប្រជុំ ។ ក្នុងករណីដែលមានសម្លេងស្មើគ្នា មតិប្រធានអង្គប្រជុំជាឧត្តមានុភាព :

-សេចក្តីព្រាងកិច្ចព្រមព្រៀង និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

-សេចក្តីព្រាងគម្រោងថវិកា ចំណូល និងចំណាយក្នុងសហគមន៍នេសាទ

-ការព្យួរសមាជិកភាពរបស់សមាជិកដែលមានកំហុស

-ការទទួលពាក្យសុំចូលជាសមាជិកថ្មី

-ការដាក់ទណ្ឌកម្មតាមបទបញ្ជាផ្ទៃក្នុង ដល់សមាជិកសហគមន៍នេសាទ ។

បន្ទាប់ពីកិច្ចប្រជុំចប់ភ្លាម ប្រធានគណៈកម្មការសហគមន៍នេសាទត្រូវចាត់ឱ្យធ្វើការជូនដំណឹងដល់សមាជិកសហគមន៍នេសាទ អំពីសេចក្តីសម្រេចរបស់ខ្លួន ។ សេចក្តីសម្រេចនៃអង្គប្រជុំរបស់គណៈកម្មការសហគមន៍នេសាទត្រូវបិទផ្សាយជាសាធារណៈ នៅទីស្តាក់ការសហគមន៍នេសាទ ឬសាលាឃុំ សង្កាត់ ក្នុងរយៈពេល ៧ ថ្ងៃយ៉ាងយូរ បន្ទាប់ពីការប្រជុំ ។

ជំពូកទី ៧
មហាសន្និបាតសហគមន៍នេសាទ

ប្រការ ១៩

មហាសន្និបាតសហគមន៍នេសាទជាអង្គប្រជុំកំពូល ដើម្បីធ្វើការអនុម័ត និងធ្វើសេចក្តីសម្រេចទាំងឡាយក្នុងនាមសហគមន៍នេសាទ ។ មហាសន្និបាតកំណើតដំបូងរបស់សហគមន៍នេសាទ ត្រូវប្រារព្ធធ្វើឡើងបន្ទាប់ពីក្រុមស្ថាបនិកបានរៀបចំរួចរាល់នូវកិច្ចការទាំងឡាយ ដែលពាក់ព័ន្ធនឹងដំណើរការមហាសន្និបាត ។

ការកោះប្រជុំមហាសន្និបាតកំណើតដំបូងរបស់សហគមន៍នេសាទ ធ្វើឡើងដោយក្រុមប្រឹក្សាឃុំ សង្កាត់ ដោយមានការជួយសម្របសម្រួលពីសមត្ថកិច្ចរដ្ឋបាលជលផល តាមការស្នើសុំរបស់ក្រុមស្ថាបនិក ហើយត្រូវមានការចូលរួមពីសមាជិកដែលបានដាក់ពាក្យស្នើសុំរួចមកហើយ ។

មហាសន្និបាតកំណើតដំបូងរបស់សហគមន៍នេសាទ អនុម័តនូវសេចក្តីសម្រេច និងកិច្ចការសំខាន់ដូចខាងក្រោម :

-អ្នកដែលដាក់ពាក្យសុំចូលជាសមាជិកសហគមន៍នេសាទ

-ឈ្មោះសហគមន៍នេសាទ

-លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ

-ការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ ។

ប្រការ ២០

មហាសន្និបាតសាមញ្ញត្រូវរៀបចំឡើង ១ ឆ្នាំម្តង ដើម្បីសរុបលទ្ធផលការងារប្រចាំឆ្នាំ និងអនុម័តនូវកិច្ចការសំខាន់ៗរបស់សហគមន៍នេសាទ ។ ក្នុងករណីចាំបាច់ សហគមន៍អាចរៀបចំមហាសន្និបាតវិសាមញ្ញតាមការស្នើសុំពីសមាជិកសហគមន៍នេសាទចំនួនមួយភាគបី(១/៣)យ៉ាងតិច ។

ប្រការ ២១

គណៈកម្មការសហគមន៍នេសាទអាចអញ្ជើញរដ្ឋបាលជលផល អាជ្ញាធរមូលដ្ឋាន ឬក្រុមប្រឹក្សាឃុំ សង្កាត់ សមត្ថកិច្ចពាក់ព័ន្ធ និងអ្នកគាំទ្រចូលរួមសង្កេតការណ៍ ឬសម្របសម្រួល ឬជាកិត្តិយសក្នុងមហាសន្និបាតសហគមន៍នេសាទ ។

ប្រការ ២២

លក្ខខណ្ឌនៃដំណើរការមហាសន្និបាត មានដូចខាងក្រោម :

-ត្រូវធ្វើការផ្សព្វផ្សាយសេចក្ដីជូនដំណឹងជាសាធារណៈ និងបិទប្រកាសនៅសាលាឃុំសង្កាត់ និងទីស្នាក់ការសហគមន៍នេសាទ

-ការកោះអញ្ជើញសមាជិកសហគមន៍នេសាទឱ្យចូលរួមមហាសន្និបាតសាមញ្ញ ត្រូវធ្វើឡើងដប់(១០) ថ្ងៃយ៉ាងតិច មុនថ្ងៃបើកមហាសន្និបាត និងបី(៣) ថ្ងៃយ៉ាងតិចមុនថ្ងៃមហាសន្និបាតវិសាមញ្ញ

-មហាសន្និបាតសាមញ្ញ ឬវិសាមញ្ញអាចប្រជុំពិភាក្សាអនុម័ត និងសម្រេចបាន លុះត្រាតែមានវត្តមានលើសពីពាក់កណ្ដាលនៃចំនួនសមាជិកសហគមន៍នេសាទ

-អង្គប្រជុំមហាសន្និបាតដឹកនាំដោយប្រធានគណៈកម្មការសហគមន៍នេសាទ ឬប្រធានអង្គប្រជុំដែលជ្រើសរើសដោយការអនុម័តក្នុងចំណោមសមាជិកវត្តមាន

-មហាសន្និបាតត្រូវអនុម័តលេខាកត់ត្រា ដើម្បីធ្វើកំណត់ហេតុ សេចក្ដីសម្រេច និងបញ្ជីវត្តមាន

-លេខាកត់ត្រា និងប្រធានអង្គប្រជុំ ត្រូវចុះហត្ថលេខាលើកំណត់ហេតុ

-សមាជិកម្នាក់មានសំឡេងតែមួយគត់ ហើយមិនអាចបញ្ជូនមនុស្សមកតំណាងបានទេ

-សេចក្ដីសម្រេចរបស់មហាសន្និបាត ត្រូវយកសំឡេងលើសពីពាក់កណ្ដាលនៃចំនួនសមាជិក ដែលមានវត្តមាន ។

ប្រការ ២៣

មហាសន្និបាតអនុម័ត :

-សេចក្ដីសម្រេចដូចមានចែងក្នុងប្រការ ១៨ កថាខណ្ឌទី ៣ នៃលក្ខន្តិកៈនេះ

-កិច្ចព្រមព្រៀង និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

-តួនាទីភារកិច្ច និងរចនាសម្ព័ន្ធរបស់គណៈកម្មការសហគមន៍នេសាទ

-ការសុំលាលែង ឬការបណ្តេញចេញពីសមាជិកភាព ឬពីសមាជិកគណៈកម្មការសហគមន៍នេសាទ

-របាយការណ៍ប្រចាំឆ្នាំរបស់គណៈកម្មការសហគមន៍នេសាទ

-គម្រោងចំណូល ចំណាយរបស់សហគមន៍នេសាទ ។

ជំពូកទី ៨

ការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ

ប្រការ ២៤

ចំនួនសមាជិកគណៈកម្មការសហគមន៍នេសាទ និងចំនួនបេក្ខជនឈរឈ្មោះ ត្រូវអនុម័តដោយមហាសន្និបាត

ប្រការ ២៥

កិច្ចដំណើរការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ គឺជាភារកិច្ចរបស់គណៈកម្មការរៀបចំការបោះឆ្នោត ដែលអនុម័យដោយមហាសន្និបាត ។ គណៈកម្មការរៀបចំការបោះឆ្នោត មានសមាសភាពពីបី(៣) ទៅប្រាំ(៥)នាក់ ដែលមានប្រធាន អនុប្រធាន និងសមាជិកតាមការកំណត់ជាក់ស្តែងរបស់មហាសន្និបាត និងត្រូវមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ មានចំណេះដឹង និងមានសីលធម៌ល្អ ។ គណៈកម្មការរៀបចំការបោះឆ្នោត ត្រូវធ្វើការប្តេជ្ញាចិត្តបង្ហាញពីភាពស្មោះត្រង់ ។

ប្រការ ២៦

គណៈកម្មការរៀបចំការបោះឆ្នោត មានភារកិច្ចដូចខាងក្រោម :

-ប្រកាសបេក្ខជនឈរឈ្មោះ

-ណែនាំអំពីនីតិវិធីនៃការបោះឆ្នោត

-បង្ហាញរចនាសម្ព័ន្ធរបស់គណៈកម្មការសហគមន៍នេសាទ

-រាប់សន្លឹកឆ្នោត និងសរុបលទ្ធផលជូនគណៈអធិបតី ដើម្បីប្រកាសជូនមហាសន្និបាត

-ភារកិច្ចរបស់គណៈកម្មការរៀបចំការបោះឆ្នោតត្រូវបញ្ចប់ដោយស្វ័យប្រវត្តិ បន្ទាប់ពីការប្រកាសលទ្ធផលបោះឆ្នោតចប់ជាស្ថាពរ ។

ប្រការ ២៧

បេក្ខជនដែលទទួលបានសំឡេងឆ្នោតគាំទ្រច្រើនជាងគេបង្អស់គឺជាប្រធានគណៈកម្មការសហគមន៍នេសាទ ។ បេក្ខជនដែលទទួលបានសន្លឹកឆ្នោតបន្តបន្ទាប់ ត្រូវទទួលតួនាទីជាអនុប្រធាន ជាសមាជិកគណៈកម្មការសហគមន៍

នេសាទតាមលំដាប់លំដោយ ។ ក្នុងករណីបេក្ខជនដែលមានសំឡេងគាំទ្រស្មើគ្នា ត្រូវជ្រើសរើសស្ត្រី ឬបោះឆ្នោតរកអ្នកដែលមានសមត្ថភាព ដោយលើកដៃយកមតិលើសពីពាក់កណ្តាលនៃចំនួនសមាជិកសហគមន៍នេសាទ ដែលចូលរួម ។

ជំពូកទី ៩

លក្ខខណ្ឌនៃការរំសាយសហគមន៍នេសាទ និងនីតិវិធីដោះស្រាយវិវាទ

ប្រការ ២៨

ការរំសាយសហគមន៍នេសាទត្រូវផ្អែកតាម :

-សំណើរបស់ខណ្ឌរដ្ឋបាលជលផលនៅពេលដែលពិនិត្យឃើញថា មានការរំលោភធ្ងន់ធ្ងរលើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍

-សេចក្តីសម្រេចមហាសន្និបាត

ក្រោយពីរំសាយសហគមន៍នេសាទ ទ្រព្យសម្បត្តិរបស់សហគមន៍ត្រូវចាត់ចែងតាមការអនុម័តរបស់មហាសន្និបាត លើកលែងតែដែននេសាទដែលត្រូវប្រគល់ជូនរដ្ឋវិញ ។

ប្រការ ២៩

ក្នុងករណីមានការតវ៉ាចោទប្រកាន់ថា ដំណើរការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទមានភាពមិនប្រក្រតី អ្នកតវ៉ាត្រូវបង្ហាញភស្តុតាងឱ្យបានច្បាស់លាស់អំពីភាពមិនប្រក្រតីនោះភ្លាម នៅមុនពេលប្រកាសលទ្ធផលបោះឆ្នោត ដើម្បីទុកលទ្ធភាពជូនមហាសន្និបាតពិនិត្យ និងសម្រេច ។

ប្រការ ៣០

វិវាទទាំងឡាយនៅក្នុងសហគមន៍នេសាទ ត្រូវដោះស្រាយដូចខាងក្រោម :

-គណៈកម្មការសហគមន៍នេសាទត្រូវសម្រុះសម្រួល និងដោះស្រាយរាល់វិវាទដែលកើតមានឡើងនៅក្នុងសហគមន៍នេសាទរបស់ខ្លួន

-ក្នុងករណីគណៈកម្មការសហគមន៍នេសាទដោះស្រាយវិវាទនោះពុំបានសម្រេច ត្រូវបញ្ជូនសំណុំរឿងនោះទៅសមត្ថកិច្ចរដ្ឋបាលជលផល ដើម្បីដោះស្រាយទៅតាមលំនានុក្រមដោយមានការចូលរួមពីអាជ្ញាធរមូលដ្ឋាន និងសមត្ថកិច្ចពាក់ព័ន្ធ តាមការចាំបាច់

-ក្នុងករណីដែលបញ្ហាវិវាទនោះនៅតែមិនអាចដោះស្រាយបាន គណៈកម្មការសហគមន៍នេសាទ និងរដ្ឋបាលជលផល ត្រូវបញ្ជូនសំណុំរឿងទៅតុលាការខេត្ត ក្រុងសាមី ដើម្បីដោះស្រាយតាមផ្លូវច្បាប់ ។

ប្រការ ៣១

សមាជិកសហគមន៍នេសាទរូបណាដែលមិនគោរពតាមលក្ខន្តិក:សហគមន៍នេសាទនេះ ត្រូវទទួលទណ្ឌកម្ម ពីគណៈកម្មការសហគមន៍នេសាទ ឬមហាសន្និបាតសហគមន៍នេសាទ ទៅតាមកម្រិតនៃទោសកំហុសរបស់ខ្លួន ។

ជំពូកទី ១០

នីតិវិធីនៃការកែប្រែលក្ខន្តិក: និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ

ប្រការ ៣២

ការកែប្រែលក្ខន្តិក: និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទត្រូវសម្រេចដោយមហាសន្និបាត ។ ការលើកសំណើកែប្រែលក្ខន្តិក: និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ ត្រូវធ្វើឡើងដោយសមាជិកយ៉ាងតិចមួយភាគបី (១/៣) នៃសមាជិកសហគមន៍នេសាទទាំងអស់ ហើយសំណើនេះត្រូវដាក់ជូនគណៈកម្មការសហគមន៍នេសាទមួយខែមុនបើកមហាសន្និបាត ។ លក្ខន្តិក: និងបទបញ្ជាផ្ទៃក្នុងនេះអាចកែប្រែបាន លុះត្រាតែមានសំឡេងយល់ព្រមលើសពីពាក់កណ្តាលនៃសមាជិកមហាសន្និបាតសហគមន៍នេសាទ ។

ជំពូកទី ១១

អវសានប្បញ្ញត្តិ

ប្រការ ៣៣

លក្ខន្តិក:សហគមន៍នេសាទនេះ ត្រូវបានអនុម័តដោយមហាសន្និបាតរបស់សហគមន៍នេសាទលើកដំបូង នៅថ្ងៃទី.....ខែ.....ឆ្នាំ ២០.... និងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខារបស់ប្រធានគណៈកម្មការសហគមន៍នេសាទ ។

ធ្វើនៅ.....ភ្នំ.....ថ្ងៃទី២០.ខែ...ភ្ជុ.....ឆ្នាំ ២០១០

ប្រធានគណៈកម្មការសហគមន៍នេសាទ

ធារ ហ្ស

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

បទបញ្ជាផ្ទៃក្នុង

សហគមន៍ទេសាទឃុំកណ្ដាល

បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ

ដើម្បីធានាការគ្រប់គ្រងសហគមន៍នេសាទឱ្យប្រព្រឹត្តទៅមានប្រសិទ្ធភាព និងមានរបៀបរៀបរយល្អ សហគមន៍នេសាទ **ឃុំកណ្ណាល** សម្រេចដាក់ចេញនូវបទបញ្ជាផ្ទៃក្នុងដូចខាងក្រោម :

ប្រការ ១

គណៈកម្មការ និងសមាជិកសហគមន៍នេសាទគ្រប់រូបត្រូវមានការស្មោះត្រង់ សាមគ្គីឯកភាពផ្ទៃក្នុង ជួយស្ថាបនាព្រមទាំងចូលរួមរៀនសូត្របច្ចេកទេសផ្សេងៗ សម្រាប់បម្រើឱ្យការរីកចម្រើនរបស់សហគមន៍នេសាទ ។

ប្រការ ២

គណៈកម្មការ និងសមាជិកសហគមន៍នេសាទ ឬបុគ្គលណាដែលបានកេងប្រវ័ញ្ចធ្វើឱ្យខូចខាត ឬបាត់បង់ទ្រព្យសម្បត្តិ និងផលប្រយោជន៍សហគមន៍នេសាទ ត្រូវទទួលទណ្ឌកម្មដូចខាងក្រោមនេះ :

- ចំពោះសមាជិកសហគមន៍នេសាទ ឬបុគ្គលដទៃទៀតត្រូវសង ឬទូទាត់ទៅតាមទំហំនៃការខូចខាតជាក់ស្តែង តាមការសម្រេចរបស់អង្គប្រជុំគណៈកម្មការសហគមន៍នេសាទ ។ ក្នុងករណីមិនព្រមសង ត្រូវដាក់ជូនមហាសន្និបាតសម្រេច
- ចំពោះគណៈកម្មការសហគមន៍នេសាទត្រូវសង ឬទូទាត់សងការខូចខាត តាមការសម្រេចរបស់មហាសន្និបាត ។ ប្រសិនបើនីតិវិធីខាងលើនេះនៅតែមិនអាចដោះស្រាយបានគឺត្រូវអនុវត្តតាមផ្លូវច្បាប់ និងបទបញ្ជាជាធរមាន ។

ប្រការ ៣

សមាជិកសហគមន៍នេសាទគ្រប់រូប ត្រូវតែចូលរួមមហាសន្និបាត និងរាល់កិច្ចប្រជុំរបស់សហគមន៍នេសាទ តាមការកោះអញ្ជើញរបស់ប្រធានគណៈកម្មការសហគមន៍នេសាទ ។ ក្នុងករណីដែលសមាជិកសហគមន៍ណាមិនបានមកចូលរួមប្រជុំចំនួន ៣ ដង ជាប់គ្នាដោយគ្មានមូលហេតុច្បាស់លាស់ ត្រូវទទួលការណែនាំពីគណៈកម្មការសហគមន៍នេសាទ ។

ករណីនៅតែមិនរាងចាល គណៈកម្មការត្រូវធ្វើសំណើទៅមហាសន្និបាតសម្រេច ដើម្បីបញ្ឈប់ពីសមាជិកភាព ។

ប្រការ ៤

សិទ្ធិដាក់ទណ្ឌកម្ម :

ក-គណៈកម្មការសហគមន៍នេសាទ

- អប់រំណែនាំលើកទី១ លើកទី២ និងលើកទី៣
- ព្រមានផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ
- ព្យួរសមាជិកភាពរបស់សមាជិកសហគមន៍នេសាទ
- បញ្ជូនបញ្ហាទំនាស់ទៅមហាសន្និបាតសម្រេច

- ផ្ទាកការនេសាទ ធ្វើកិច្ចសន្យាបញ្ឍប់ការនេសាទ និងរាយការណ៍ជាបន្ទាន់ទៅសមត្ថកិច្ចរដ្ឋបាលជលផល ចំពោះការនេសាទលើទំហំ ចំនួន និងខុសប្រភេទ ពេលវេលា ទីតាំងតាមកំណត់នៅក្នុងផែនការគ្រប់គ្រង និងកិច្ចព្រមព្រៀងនៅក្នុងកន្លែងនេសាទសហគមន៍ ។

១-មហាសន្និបាត

- អនុម័តការបណ្តេញចេញដូចមានចែងក្នុងប្រការ ៧ នៃលក្ខន្តិក:សហគមន៍នេសាទ
- សម្រេចលើសំណងខូចខាតទ្រព្យសម្បត្តិសហគមន៍នេសាទ
- សម្រេចដាក់ទណ្ឌកម្មដល់គណៈកម្មការ
- ដាក់ទណ្ឌកម្មដល់សមាជិក ឬបុគ្គលដទៃទៀត ដែលគណៈកម្មការមិនអាចដោះស្រាយបាន ។

ប្រការ ៥

សមាជិកគណៈកម្មការសហគមន៍នេសាទគ្រប់រូប ត្រូវរាយការណ៍ជូនគណៈកម្មការសហគមន៍នេសាទ អំពីសម្ភារៈឧបករណ៍នេសាទ ដែលគ្រួសារនីមួយៗប្រើប្រាស់នៅក្នុងកន្លែងនេសាទសហគមន៍ ។

ប្រការ ៦

សមាជិកសហគមន៍នេសាទអាចប្រើប្រាស់ឧបករណ៍នេសាទជាលក្ខណៈគ្រួសារ ដូចមានចែងខាងក្រោម :

- លបក្តាមមានក្រឡាធំជាង ៦ សង់ទីម៉ែត្រ
- មងក្តាមមានក្រឡាធំជាង ៨ សង់ទីម៉ែត្រ
- មងបង្គាមានក្រឡាធំជាង ៣.៨ សង់ទីម៉ែត្រ
- លបត្រីក្រឡាធំជាង ៦ សង់ទីម៉ែត្រ
- មងបេកាក្រឡាធំជាង ៨ សង់ទីម៉ែត្រ
- មងត្រីការាវក្រឡាធំជា ៨ សង់ទីម៉ែត្រ
- មងត្រីក្បកក្រឡាធំជាង ៣.៥ សង់ទីម៉ែត្រ
- សំណាញ់ក្រឡាធំជាង ៣.៥ សង់ទីម៉ែត្រ
- មងត្រីឆ្ពង់ក្រឡាធំជាង ១០ សង់ទីម៉ែត្រ
- មងត្រីផ្ទោង មានប្រវែងមិនលើសពី ៣០០ ម៉ែត្រ
- មងត្រីព្រលួស មានប្រវែងមិនលើសពី ៣០០ ម៉ែត្រ
- លបក្តាមមានចំនួនមិនលើសពី ៣០០ លប
- មងក្តាមមានប្រវែងមិនលើសពី ២០០ ម៉ែត្រ
- មងបង្គាមានប្រវែងមិនលើសពី ៥០០ ម៉ែត្រ
- លបត្រីចំនួនមិនលើសពី ៥០ លប
- សន្ទូចរនងមិនលើស ៥០០ ផ្ទៃ

- មងត្រីកាម៉ុងមិនលើសពី ៥០០ ម៉ែត្រ
- មងបេកាប្រវែងមិនលើសពី ៥០០ ម៉ែត្រ
- មងត្រីឆ្គង់មានប្រវែងមិនលើសពី ៣០០ ម៉ែត្រ
- លបមឹកមានចំនួនមិនលើសពី ១០០ លប
- សន្ទូចបង្ហែលមិនលើសពី ២០០ ផ្ទៃ

ប្រការ ៧

ហាមឃាត់ដាច់ខាតនូវសកម្មភាពដូចខាងក្រោម :

- ការកាប់ព្រៃលិចទឹកគ្រប់ប្រភេទដើម្បីធ្វើអាជីវកម្ម
- ការកាប់រាន និងដុតបំផ្លាញព្រៃលិចទឹក
- ការធ្វើនេសាទចាប់ផ្សោត ជ្រូកទឹក និងអណ្តើកសមុទ្រគ្រប់ប្រភេទ
- ការធ្វើនេសាទចាប់កូនត្រីតុកកែ ត្រីឆ្គង់ ដែលមានចំនួនលើសពី ១២ ក្បាល ក្នុង ១ គីឡូក្រាម
- ការចាប់ និងទិញ-លក់កូនក្តាមដែលមានចំនួនលើសពី ១២ ក្បាល ក្នុង ១ គីឡូក្រាម
- ការធ្វើនេសាទដោយប្រើឧបករណ៍ ឈិបយន្ត (ឌុន) អូសអូស មងហោះ អូនខ្ទ ថ្នាំបំពុល ត្រឿងផ្ទុះ ឧបករណ៍ឆក់ ផ្ទងផ្ទាង ដាក់សំរ៉ាស់ ។
- ការធ្វើនេសាទទាំងឡាយណាដែលបង្កមហន្តរាយដល់ ផ្កាថ្ម និងស្មៅសមុទ្រ
- ការបរបាញ់ ដាក់អន្ទាក់ ឬប្រើមធ្យោបាយផ្សេងៗ ដើម្បីចាប់សត្វព្រៃគ្រប់ប្រភេទ
- ការចោលកាកសំណល់រឹង និងរាវ ដូចជា កំប៉ុង ដប ថង់ប្លាស្ទិក សំរ៉ាម និងប្រេងឥន្ធនៈគ្រប់ប្រភេទ ចូលទៅក្នុងព្រៃក ឬសមុទ្រ
- ការធ្វើវ៉ារីវប្ចកម្មគ្រប់ប្រភេទ ដោយគ្មានច្បាប់អនុញ្ញាតពីជំនាញជលផល

ប្រការ ៨

សមាជិកសហគមន៍នេសាទដែល :

- ប្រព្រឹត្តផ្ទុយ ឬរារាំងមិនឱ្យសមាជិកដទៃអនុវត្តសិទ្ធិ និងកាតព្វកិច្ចដូចក្នុងប្រការ ៥ នៃលក្ខន្តិកៈ ត្រូវព្យួរសមាជិកភាព ដោយគណៈកម្មការសហគមន៍នេសាទ ឬបណ្តេញចេញពីសមាជិកភាពដោយមហាសន្និបាត
- មិនចូលរួមថែរក្សាការពារធនធានជលផល ឬមិនរាយការណ៍អំពីសកម្មភាពបទល្មើសជលផល ត្រូវព្រមានដោយគណៈកម្មការសហគមន៍នេសាទ
- ប្រើប្រាស់ឧបករណ៍ហាមឃាត់ ធ្វើនេសាទខុសច្បាប់ កាប់ឆ្ការរានព្រៃលិចទឹក ព្រៃកោងកាង បំផ្លាញផ្កាថ្ម ឬស្មៅ សមុទ្រ ត្រូវទទួលការផ្តន្ទាទោសតាមច្បាប់ស្តីពីជលផល
- ធ្វើនេសាទក្នុងកន្លែងអភិរក្សរបស់សហគមន៍នេសាទ ត្រូវផ្អាកការនេសាទ ហើយធ្វើកិច្ចសន្យាបញ្ឈប់ការនេសាទ និងរាយការណ៍ជាបន្ទាន់ទៅអាជ្ញាធរមូលដ្ឋាន និងរដ្ឋបាលជលផលមានសមត្ថកិច្ច

- អនុវត្តផ្ទុយនឹងបទប្បញ្ញត្តិច្បាប់ លក្ខន្តិក: បទបញ្ជាផ្ទៃក្នុង កិច្ចព្រមព្រៀង ឬផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ត្រូវផ្ទាកការនេសាទ ទទួលការព្រមានជាលាយលក្ខណ៍អក្សរ ធ្វើកិច្ចសន្យាបញ្ឈប់ការនេសាទ និងរាយការណ៍ជា បន្ទាន់ជូនទៅរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីដោះស្រាយតាមច្បាប់ ។

ប្រការ ៩

ចំពោះអ្នកប្រើប្រាស់ធនធានជលផលដែលមិនមែនជាសមាជិកសហគមន៍នេសាទ អាចមានសិទ្ធិចេញចូល និងនេសាទក្នុងកន្លែងនេសាទសហគមន៍ ប៉ុន្តែត្រូវជូនព័ត៌មានដល់គណៈកម្មការសហគមន៍នេសាទ ហើយធ្វើកិច្ចសន្យា និងគោរពកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ លក្ខន្តិក: បទបញ្ជាផ្ទៃក្នុង និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ។

ក្នុងករណីដែលអ្នកប្រើប្រាស់ធនធានជលផលដែលមិនមែនជាសមាជិកសហគមន៍នេសាទ មិនបានគោរពតាមប្រការនេះ គណៈកម្មការសហគមន៍នេសាទមានសិទ្ធិបញ្ឈប់សកម្មភាពនេសាទរបស់ជននោះ ហើយធ្វើការអប់រំណែនាំ ។

ប្រការ ១០

បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទនេះ ត្រូវបានអនុម័តដោយមហាសន្និបាតរបស់សហគមន៍នេសាទលើកដំបូង នៅថ្ងៃទី.....ខែ.....ឆ្នាំ ២០.... និងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាដោយប្រធានគណៈកម្មការសហគមន៍នេសាទ ។

ធ្វើនៅកណ្តាល ,ថ្ងៃទី.ពេ.ធ.ខែ.....ឆ្នូ.....ឆ្នាំ ២០១០

ប្រធានគណៈកម្មការសហគមន៍នេសាទ

ណាង ហ្ស

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ពាក្យស្នើសុំ

បង្កើតសហគមន៍នេសាទឃុំកណ្តាល

យើងខ្ញុំទាំងអស់គ្នាចំនួន ២៤៣ គ្រួសារ ជាប្រជាពលរដ្ឋរស់នៅក្នុងភូមិប្រលានភូមិធ្ងន់ និងភូមិកណ្តាល ឃុំកណ្តាល ស្រុកបូទូមសាគរ ខេត្តកោះកុង ។

សូមគោរពជូន

ឯកឧត្តម រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

តាមរយៈ : -លោកមេឃុំកណ្តាល

-លោកអភិបាលស្រុកបូទុមសាគរ

-លោកនាយខណ្ឌរដ្ឋបាលជលផលកោះកុង

-លោកនាយអធិការដ្ឋានរដ្ឋបាលជលផលសមុទ្រ

-ឯកឧត្តម អភិបាលខេត្តកោះកុង

-ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាប្រធានរដ្ឋបាលជលផល

កម្មវត្ថុ : ស្នើសុំបង្កើតសហគមន៍នេសាទឃុំកណ្តាល ដើម្បីគ្រប់គ្រង និងប្រើប្រាស់ធនធានធម្មជាតិជលផលប្រកបដោយនិរន្តរភាព ។

យោង : -ព្រះរាជក្រឹត្យលេខ នស/រកត/០៥០៥/២៤០ ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០៥ ស្តីពីការបង្កើត សហគមន៍នេសាទ ។

-ច្បាប់ស្តីពីជលផល លេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៦ ។

-អនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មិនា ឆ្នាំ ២០០៧ ស្តីពីការគ្រប់គ្រងសហគមន៍នេសាទ ។

-ប្រកាសលេខ ៣១៦ ប្រក.កសក ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៧ ស្តីពីគោលការណ៍ណែនាំអំពីសហគមន៍នេសាទ ។

ភ្ជាប់ជាមួយនូវ :-លក្ខន្តិកៈសហគមន៍ ចំនួន ០១ ច្បាប់

-ផែនទីសហគមន៍ ចំនួន ០១ សន្លឹក

-ស្នាមមេដៃសមាជិក ចំនួន ០១ ច្បាប់

-បញ្ជីឈ្មោះគណៈកម្មការ ចំនួន ០១ ច្បាប់

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ យើងខ្ញុំទាំងអស់គ្នាសូមជម្រាបជូនឯកឧត្តមមេត្តាជ្រាបថា : រយៈកាលកន្លងមកធនធានជលផលនៅក្នុងឃុំកណ្តាល ត្រូវទទួលរងនូវការបំផ្លិចបំផ្លាញយ៉ាងអនាធិបតេយ្យពីសំណាក់ជនល្មើស ដែលអាចឈានទៅរកការវិនាសហិនហោច និងជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅពេលបច្ចុប្បន្ន ក៏ដូចជាទៅអនាគត ។ ដូច្នេះដើម្បីធានាបាននូវការគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តរភាព និងលើកស្ទួយជីវភាពប្រជាពលរដ្ឋឱ្យបានល្អប្រសើរឡើង យើងខ្ញុំទាំងអស់គ្នាសូមស្នើសុំចូលរួមគ្រប់គ្រង ការពារ និងប្រើប្រាស់ធនធានជលផល ក្នុងឃុំកណ្តាលឱ្យសមស្របទៅតាមច្បាប់ ។ ម្យ៉ាងទៀត ដើម្បីឱ្យដំណើរការនៃការគ្រប់គ្រងសហគមន៍នេសាទឃុំកណ្តាល ប្រព្រឹត្តទៅបានល្អប្រសើរ និងជោគជ័យ យើងខ្ញុំទាំងអស់គ្នានឹងសហការជាមួយអាជ្ញាធរដែនដី និងស្ថាប័នជំនាញពាក់ព័ន្ធ ។

អាស្រ័យហេតុនេះ សូមឯកឧត្តមមេត្តាពិនិត្យ និងសម្រេចដោយអនុគ្រោះ ។
សូមឯកឧត្តម មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ ។

ធ្វើនៅកណ្តោល ថ្ងៃទី ២០ ខែ ១ ឆ្នាំ ២០១០
តំណាងប្រជាជនទាំង ២៤៣ គ្រួសារ
ហត្ថលេខា

ហេង ហួន

លេខ.០ជ.ជ/១១ យស
បានឃើញ និង បញ្ជូនមកលោក
នាយខណ្ឌរដ្ឋបាលជលផលកោះកុង
មេត្តាជួយសំរួល ដោយក្តីអនុគ្រោះ ។
ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១១
អភិបាលស្រុកបូទុមសាគរ

លេខ.០២០/ សហ.ស.ត
បានឃើញ និង បញ្ជូនមកលោកអភិបាលស្រុក
មេត្តាជួយសំរួល ដោយក្តីអនុគ្រោះ ។
ថ្ងៃទី ០២ ខែ ០៤ ឆ្នាំ ២០១១
មេឃុំកណ្តោល

លេខ.០ជ០ យ.ជ.ជ
...ជានឃើញ...ដឹងតាមការដាស...
...ឯកឧត្តមអភិបាលខេត្តកោះកុង
...«ដើម្បីតាមដាន និង ស្រាវជ្រាវ»
ថ្ងៃទី ០៤ ខែ ០ មេសា ឆ្នាំ ២០១១
នាយអភិការដ្ឋានរដ្ឋបាលជលផលសមុទ្ર

លេខ.០១ជ ខរ.ពក
បានឃើញ និង បញ្ជូនមក
លោកនាយអភិការដ្ឋានរដ្ឋបាលជលផលសមុទ្ર
មេត្តាជួយសំរួល ដោយក្តីអនុគ្រោះ ។
ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១១
នាយខណ្ឌរដ្ឋបាលជលផលកោះកុង

លេខ.....រជផ
.....
.....
.....
ថ្ងៃទី.....ខែ.....ឆ្នាំ ២០១១
ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា
ប្រធានរដ្ឋបាលជលផល

លេខ.ជ០ជ.ជ.ជ....ខពក
...ជានឃើញ...ដឹងតាមការដាស...
...ឯកឧត្តមអភិបាលខេត្ត...
...ដើម្បីតាមដាន និង ស្រាវជ្រាវ...
ថ្ងៃទី ០៤ ខែ ០ មីនា ឆ្នាំ ២០១១
អភិបាលខេត្ត

អេង . គឹមឆាង

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ១៧០ ប្រ.ត. កសក

ប្រកាស

ស្តីពី

ការចុះបញ្ជីសហគមន៍នេសាទចំនួន០៤ នៅខេត្តកោះកុងនិងខេត្តតាកែវ

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៥/២៤០ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៥ ស្តីពីការបង្កើតសហគមន៍នេសាទ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលំអដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្មនិងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ២៥ អនក្រ.បក ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៧ ស្តីពីការគ្រប់គ្រងសហគមន៍នេសាទ
- បានឃើញអនុក្រឹត្យលេខ១២៣ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្តីពីការកំណត់ប្រភេទផលផលិតផលជលផលដែលកំពុងរងគ្រោះថ្នាក់
- បានឃើញប្រកាសលេខ ៦៨១ ប្រក.កសក.ប ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១០ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យនិងមន្ទីរពិសោធន៍ចំណុះនាយកដ្ឋាន និងវិទ្យាស្ថានក្រោមឱវាទរដ្ឋបាលជលផល
- បានឃើញប្រកាសលេខ ៣១៦ ប្រក.កសក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៧ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីគោលការណ៍ណែនាំអំពីសហគមន៍នេសាទ
- យោងតាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាប្រធានរដ្ឋបាលជលផល

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
No. 200 Preah Norodom Blvd, Sangkat Tonle Basak, Khan Chamkarmon Phnom Penh, Cambodia
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129 Fax : (855) 23 217 320

សម្រេច

ប្រការ ១.-

ត្រូវបានចុះបញ្ជីជាផ្លូវការនិងទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នូវសហគមន៍នេសាទ ចំនួន០៤រួមមាន៖ ខេត្តកោះកុងចំនួន០៣ សហគមន៍និងខេត្តតាកែវចំនួន០១ សហគមន៍ ដែលមានឈ្មោះសហគមន៍នេសាទ ចំនួនសមាជិក ចំនួនគណៈកម្មការ ទំហំកន្លែងនេសាទសហគមន៍ ឈ្មោះឃុំ ស្រុក ខេត្ត និងនិយាមកាជាចំណុចគោលនៃព្រំប្រទល់កន្លែងនេសាទសហគមន៍ ដូចមាននៅក្នុងតារាងនិងផែនទីកន្លែងនេសាទសហគមន៍នីមួយៗជាឧបសម្ព័ន្ធ ភ្ជាប់ប្រកាសនេះ ។

ប្រការ ២.-

ព្រំប្រទល់កន្លែងនេសាទសហគមន៍នីមួយៗ ដែលបានកំណត់ក្នុងផែនទី ដូចមានចែងក្នុងប្រការ ១ ខាងលើ ត្រូវបានទទួលស្គាល់ដោយនាយខណ្ឌរដ្ឋបាលជលផល អាជ្ញាធរដែនដី ប្រធានរដ្ឋបាលជលផល និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ប្រការ ៣.-

ទំហំកន្លែងនេសាទសហគមន៍ និយាមកាជាចំណុចគោលនៃព្រំប្រទល់កន្លែងនេសាទសហគមន៍ ចំនួនភូមិ និងទីតាំងភូមិសាស្ត្ររបស់សហគមន៍ ដូចមានចែងក្នុងប្រការ ១ អាចកែប្រែបានតាមការចាំបាច់ដោយប្រកាសក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ប្រការ ៤.-

ប្រកាស ឬសេចក្ដីសម្រេចទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៥.-

អគ្គលេខាធិការ អគ្គាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្ម នាយកខុទ្ទកាល័យ ប្រធានរដ្ឋបាលជលផល ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ ប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រធានមន្ទីរកសិកម្មខេត្តពាក់ព័ន្ធ និងប្រធានសហគមន៍នេសាទត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ១២ ឆ្នាំ ២០១២

រដ្ឋមន្ត្រី

ជាក់ស្តែ

ទីកន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- សាលាខេត្តពាក់ព័ន្ធ
- ដូចប្រការ ៥
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធ: ភ្ជាប់ប្រកាសលេខ ...២៧០ ប្រកាស... ចុះថ្ងៃទី ...០៤... ខែ ...១២... ...ឆ្នាំ២០១២

សហគមន៍នេសាទក្នុងខេត្តកោះកុងនិងខេត្តតាកែវ

ល.រ	ឈ្មោះសហគមន៍នេសាទ	ចំនួនសមាជិក	ចំនួនសមាជិកគណៈកម្មការសហគមន៍	ទំហំផ្ទៃសហគមន៍ (ហិកតា)	ភូមិ	ឃុំ/សង្កាត់	ស្រុក/ក្រុង	Projection :UTM, Everest 1830, Datum : Indian 1960, Zone : 48 N	
								(X,Y)	(X,Y)
១-ខេត្តកោះកុង									
១	ឃុំភ្ញីមាស	១៧៩	៧	៤.៨០៨	ភ្ញីមាស តានីកៀនក្រឡាញ់	ភ្ញីមាស	គិរីសាគរ	A. (292278, 1225766) B. (293312, 1232813) C. (291811, 1232905)	D. (289896, 1221526) E. (291298, 1219771) F. (293189, 1219186)
២	ឃុំកណ្តាល	២៤២	៧	២.៥៦០	ធ្ងង់	កណ្តាល	បុទុមសាគរ	A. (337275, 1234321) B. (342340, 1234094)	C. (337654, 1234701) D. (339551, 1224970)
៣	ឃុំជ្រោយប្រស់	១៨០	៩	១១.០៨៥	ថ្មី	ជ្រោយប្រស់	កោះកុង	A. (284911, 1243986) B. (285169, 1245040) C. (285921, 1246408)	D. (291899, 1259152) E. (292834, 1255007) F. (294126, 1257143)
២-ខេត្តតាកែវ									
១	បាស្រែ	៦១៤	៧	១.៤១១	បាស្រែ ពួនកក តាអ៊ី ព្រៃបាសឹង ស្វាយខាងជើង និងស្វាយខាងត្បូង	បាស្រែ	អង្គរបូរី	A. (497000, 1223000) B. (503000, 1223000) C. (503014, 1220004)	D. (499640, 1219974) E. (500385, 1221404) F. (500280, 1221530)

បានឃើញនិងឯកភាព

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ១២ ឆ្នាំ២០១២

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ

ជ.ស.ណារុន

ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា

ប្រធានផ្នែកជលផល ...

ណារ៉ា ...